ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 09-Apr-2015, 13:41
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសជ

**ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥**

**ម៉ោង ០៨:០៣នាទី**

**សវនាការលើកទី២៦៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៊ាង

លោក រ៉ូជឺ ហ្វីលីព *(Mr. Roger Phillips)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សួន វិសាល

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ
*(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរលក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោកស្រី ស៊ីន សុវ៉ន

លោក ហុង គឹមសួន

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្ល សុទ្ធារី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល | បារាំង |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក វីឆាដ ឌុដម៉ាន (2-TCW-923) | អង់គ្លេស |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក រីឆាដ ខុដម៉ាន** (2-TCW-923)


សួរបន្តដោយលោក រ៉ិចទ័រ កូប៉េ ផ្តើមពី ........................................ទំព័រ ៣

សួរដោយលោក ឌេល លីសាក់ ផ្តើមពី ........................................ទំព័រ ៦

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ........................................ទំព័រ ៣០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:០៣:៥០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅព្រឹកនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី រីឆាដ ឌុដម៉ាន តាមរយៈប្រព័ន្ធសោតទស្សន៍ពីសហរដ្ឋអាមេរិកមក។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានបុគ្គលភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការព្រឹកនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន!

សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មនៅថ្ងៃនេះ គឺលោក រីឆាដ ឌុដម៉ាន តាមរយៈប្រព័ន្ធសោតទស្សន៍ពីសហរដ្ឋអាមេរិក។ តាមការបញ្ជាក់ពីផ្នែកបច្ចេកទេសសោតទស្សន៍បានជូនដំណឹងថា ការរៀបចំផ្នែកបច្ចេកទេសសម្រាប់ការស្ដាប់សក្ខីកម្មនេះបានរៀបចំរួចរាល់ហើយ រីឯសាក្សីក៏បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ការផ្ដល់សក្ខីកម្មនេះដែរ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ កញ្ញា ជា ស៊ីវហ័ង។ បាទ ជាបឋមនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាពេលខាងមុខឲ្យមានប្រសិទ្ធ-

ភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០១៥។ ដោយមេធាវីការពារក្ដីរបស់ខ្លួន បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៨:០៦:២៥]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យ ព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា នៅតែមានអាការៈឈឺចង្កេះរ៉ាំរ៉ៃ មិនអាចអង្គុយយូរ និងផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

សួស្ដីលោក វីឆាដ ឌុដម៉ាន!

[០៨:០៧:៥០]

**លោក វីឆាដ ឌុដម៉ានៈ**

ជម្រាបសួរលោកប្រធាន។

**ប្រធានអង្គជំនុំៈ**

បាទ នៅពេលនេះ អង្គជំនុំជម្រះបន្តស្ដាប់សក្ខីកម្មរបស់លោកជាបន្តទៀត ដែលនឹងសួរដោយ

ភាគីមេធាវីការពារក្តី។ តើលោកបានត្រៀមខ្លួនរួចហើយឬនៅលោក រីឆាដ ឌុដម៉ាន?

**លោក រីឆាដ ឌុដម៉ាន៖**

បាទ ខ្ញុំត្រៀមរួចរាល់ហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី។

សូមអញ្ជើញបាទ!

**លោក វិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម សហការីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក វិចទ័រ កូប៉េះ**

**ស៖** អរុណសួស្តីលោក ឌុដ ខ្ញុំជិតនឹងចប់ការតាំងសំណួររបស់ខ្ញុំហើយ ដូចខ្ញុំជម្រាបជូនលោកកាលពីម្សិលមិញ។ ខ្ញុំចង់ឲ្យលោកស្តាប់នូវឈុតខ្សែវីដេអូមួយនៃកិច្ចសម្ភាសន៍ ឬក៏ថាជាសុន្ទរកថាដែល ប៉ុល ពត បាននិយាយជាមួយលោក និងជាមួយ អេលីហ្សាបេត បេកយ័រ នៅខែធ្នូ ឆ្នាំ១៩៧៨។ លោក ឌុដម៉ាន ខ្ញុំជឿថា ពីម្សិលមិញនេះ លោកបានទទួលតាមរយៈមេធាវីរបស់លោកនូវប្រតិចារឹកប្រហែលជា៩នាទីកន្លះ។ តើវាត្រឹមត្រូវដែរឬទេ ប្រតិចារឹកហ្នឹង? ហើយលោកបាន១អានប្រតិចារឹកនេះហើយឬនៅ?

[០៨:១០:០០]

**លោក រីឆាដ ឌុដម៉ាន៖**

**ឆ៖** ខ្ញុំបានអានហើយ ខ្ញុំបានស្តាប់ទៅខ្សែវីដេអូនេះភាគច្រើនហើយ មុននឹងចាប់ផ្តើមធ្វើការសាកសួររូបខ្ញុំនេះ។

**ស៖** ខ្ញុំសូមអរគុណច្រើនលោក ឌុដម៉ាន។

**លោក វិចទ័រ កូប៉េះ**

លោកប្រធាន ដើម្បីជាផលប្រយោជន៍សម្រាប់លោក នួន ជា ក៏ដូចជាសាធារណជន ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីចាក់បញ្ចាំងខ្សែវីដេអូរយៈពេល៩នាទីកន្លះនេះ នៅក្នុងបន្ទប់សវនាការ។ ខ្ញុំយល់ថា អង្គភាពផ្នែកខាងសោតទស្សន៍គឺថាអាចនឹងជួយចាក់វីដេអូនេះបាន។ សំណើសុំរបស់ខ្ញុំនេះ គឺ

ថាគុណភាពនេះមិនល្អទេ គុណភាពវីដេអូនេះ ដែលថានៅពេលដែល ប៉ុល ពត និយាយជាភាសាខ្មែរទៅ វាស្តាប់ឮតិចពេក ហើយ ជួន ប្រសិទ្ធិ ក៏បកប្រែឮខ្លាំងៗ ការបកប្រែគឺថាអាចស្តាប់បាន។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីចាក់បញ្ចាំងខ្សែវីដេអូនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ បុគ្គលិកផ្នែកសោតទស្សន៍ចាក់នូវខ្សែវីដេអូតាមសំណើសុំរបស់មេធាវី វ៉ិចទ័រ កូប៉េ។

[០៨:១១:២៦]

*(ការបង្ហាញឯកសារសំឡេង)*

*"...ប៉ុន្តែសភាពការណ៍នៃកម្ពុជាប្រជាធិបតេយ្យបច្ចុប្បន្ន ដូចជាលោកទើបជ្រាបហើយ ហើយម្យ៉ាងទៀត ក៏បានយល់ពីកម្ពុជាប្រជាធិបតេយ្យបានកំពុងត្រូវរងគ្រោះដោយយួនឈ្លានពាន។ ស្តាលិកទាំងមូលចាប់អារម្មណ៍ក្នុងពេលបច្ចុប្បន្ននេះ អំពីការឈ្លានពានរបស់យួនមកលើកម្ពុជាប្រជាធិតេយ្យ ហើយកំពុងព្រួយបារម្ភចំពោះការវាយលុករបស់យួនមកលើកម្ពុជា ក្រែងលោកម្ពុជាទប់ទល់នឹងយួនមិនបាន ហើយប៉ះពាល់ទៅដល់អាស៊ីអាគ្នេយ៍ និងប៉ះពាល់ទៅដល់សន្តិភាពនៅអាគ្នេយ៍--"*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង)*

[០៨:១៣:១៣]

**ប្រធានអង្គជំនុំ៖**

ស្តុបត្រង់ហ្នឹងសិនហើយ។ បាទៗ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំក៏បាន គឺថាសម្រង់ដែលបានចាប់ផ្តើមនៅត្រង់នាទី៣០:១៥ គឺថាខ្ញុំយល់ឃើញពេលឮសួរវីដេអូនេះ គឺថាវាខុសគ្នា។ គឺឯកសារ D28R នៅត្រង់នាទី៣៣:១៥។

**ប្រធានអង្គជំនុំ៖**

បុគ្គលិកផ្នែកសោតទស្សន៍រៀបចំសាជាថ្មី។ អំមិញមានការភាន់ច្រឡំ ណ៎! ហើយវីដេអូក្រោយនេះ គឺត្រង់នាទី៣៣:១៥។

[០៨:១៤:៤៨]

*(ការបង្ហាញឯកសារសំឡេង)*

*"សុទ្ធតែកំនួច (ឮមិនច្បាស់) ប្រជាជននៅក្នុងប្រទេស -- អឺ! វាទៅពឹងពាក់អន្តរជាតិនិយមសូវៀត ឬក៏បក្សសម្ព័ន្ធវ៉ាសូវី មិនមែនជាកត្តាកំណត់។ សុទ្ធតែកំនួច (ឮមិនច្បាស់) ប្រជាជននៅក្នុងប្រទេស។ វាតទីនិយមសូវៀត អន្តរជាតិនិយមសូវៀត និងបក្សសម្ព័ន្ធវ៉ាសូវីនៅឆ្ងាយពីកម្ពុជា និងអាស៊ីអាគ្នេយ៍។ នាំទ័ពមកពីនុំងដើម្បីវ៉ៃកម្ពុជា វាត្រូវធ្វើដំណើរឆ្ងាយ ហើយត្រូវដឹកអ្វីៗទាំងអស់មក ពីព្រោះគ្មានអីពឹងពាក់នៅខាងវៀតណាម ព្រោះវៀតណាមវាអត់បាយស៊ីខ្លួនវា។ ទីប្រឹក្សាសូវៀតមានច្រើន កាន់តែលំបាកឲ្យយើងទៀត។ បើបញ្ជូនកងទ័ពរបស់បក្សសម្ព័ន្ធវ៉ាសូវីមកទៀតរឹតតែលំបាកឲ្យប្រជាជនវៀតណាម។ នេះម្យ៉ាង ហើយម្យ៉ាងទៀត បក្សសម្ព័ន្ធវ៉ាសូវីក៏ត្រូវប្រឈមមុខនឹងកតិកាសញ្ញាអាត្លង់ទិកខាងជើង។ វាតទីនិយមអន្តរជាតិសូវៀត និងបក្សសម្ព័ន្ធវ៉ាសូវីមកវ៉ៃកម្ពុជា និងអាស៊ីអាគ្នេយ៍ត្រូវគិតគូរអឺរ៉ុប។ សភាពការណ៍នៅអឺរ៉ុបខាងកើតមិនមែនជាសភាពការណ៍វានឹងន មានស្ថិរភាពឲ្យវាតទីនិយមអន្តរជាតិសូវៀតស្ងប់ចិត្ត ពីព្រោះកំពុងមានបារម្ភណាស់ បើដកកម្លាំងនេះ ទទឹងទទែងមកវ៉ៃខាងកម្ពុជា និងអាស៊ីអាគ្នេយ៍ ក៏ត្រូវការពារខាងអឺរ៉ុប។ អ៊ីចឹងទេ ម៉្យាងទៀត កម្ពុជាក្តី ប្រទេសទាំងឡាយនៅអាស៊ីអាគ្នេយ៍ក្តី ប្រទេសទាំងឡាយនៅអាស៊ី និងសកលលោកក្តីមិនមែនសុខចិត្តឲ្យសូវៀត និងបក្សសម្ព័ន្ធរបស់សូវៀតមកយកកម្ពុជា និងយកអាស៊ីអាគ្នេយ៍បានតាមចិត្តទេ។*

*ដូច្នេះយើងខ្ញុំវិភាគថា យួនឈ្លានពានកម្ពុជាដោយរួមនឹងផែនការជាយុទ្ធសាស្ត្រជាមួយភាតីនិយមអន្តរជាតិ ដើម្បីអនុវត្តយុទ្ធសាស្ត្រសហព័ន្ធឥណ្ឌូចិនរបស់វា យុទ្ធសាស្ត្រដណ្តើមយកអាស៊ីអាគ្នេយ៍ វាត្រូវបរាជ័យធ្ងន់ធ្ងរជាងមួយឆ្នាំ។ ពួកវាតទីកម្ពុជានេះ វាកំពុងជំរុញសង្គ្រាមឈ្លានពានកម្ពុជាតទៅទៀតដោយខិតខំអនុវត្តនូវសកលភាវូនីយកម្មសេដ្ឋកិច្ច ត្រូវយកបក្សសម្ព័ន្ធរបស់វ៉ាសូវីមករកវ៉ៃកម្ពុជា។ ដូច្នេះរឿងនេះមិនមែនរឿងជម្លោះព្រំដែនអីធម្មតាទេ។ ជាខាងទ័ពយុទ្ធសាស្ត្ររបស់យួនសម្រាប់សហព័ន្ធឥណ្ឌូចិនរបស់វា និងយុទ្ធសាស្ត្ររបស់សូវៀតសម្រាប់អាស៊ីអាគ្នេយ៍ និងអាស៊ីរបស់វា និងសកលលោករបស់វា។ ឥឡូវសាកលលោកឃើញច្បាស់។ ក្នុងបក្សសម្ព័ន្ធវ៉ាសូវីក៏មានកម្លាំងប្រឆាំងវាដែរ។ ដូចប្រទេសនានាក្នុងសកលលោកក៏ប្រឆាំង។"*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង)*

[០៨:២៤:៤៨]

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** លោក ឌុងម៉ាន លោកបានស្តាប់ខ្សែវីដេអូនេះដែរទេ?

**លោក វីឆាង ឌុងម៉ានៈ**

**ឆៈ** បាទ បានស្ដាប់ហើយ។

**សៈ** ខ្ញុំដឹងថាវាមានរយៈពេលយូរយារណាស់មកហើយ ដែលកិច្ចសម្ភាសន៍នេះត្រូវបានធ្វើឡើង គឺថា យូរយារហើយ ប៉ុន្តែក្រោយពីស្ដាប់កិច្ចសម្ភាសន៍នេះ តើលោកចាំទេ?

**ឆៈ** ខ្ញុំអត់ចាំទេ។

**សៈ** លោកចាំថាមានប្រតិកម្មណាពីខាងភាគីរបស់លោក -- លោកមានប្រតិកម្មអ្វីដែលទេ ក្រោយពីកិច្ចសម្ភាសន៍នេះ ឬក៏ថា ដោយសារកិច្ចសម្ភាសន៍នេះវាយូរយារណាស់មកហើយ?

**ឆៈ** ខ្ញុំមិនមានប្រតិកម្មអីទេ ខ្ញុំមិនចាំទេ។

**សៈ** ក្នុងដំណាក់កាលនេះ តើលោកមានប្រតិកម្មណាមួយចំពោះកិច្ចសម្ភាសន៍នេះទេ ដែលអាចបង្ហាញជូនទៅអង្គជំនុំជម្រះបានដែរឬទេ?

**ឆៈ** ខ្ញុំស្ដាប់សំណួរលោកអត់បានទេ។

**សៈ** តើមានអ្វីដែលលោកត្រូវនិយាយពាក់ព័ន្ធទៅនឹងកិច្ចសម្ភាសន៍នេះទេ ក្រោយពីលោកបានស្ដាប់ហើយ?

**ឆៈ** ខ្ញុំមិនមានយោបល់អ្វីទេ។

**លោក វ៉ិចទ័រ កូប៉េៈ**

លោកប្រធានខ្ញុំអស់សំណួរហើយ សូមអរគុណច្រើន។ លោក ឌុងម៉ាន សូមអរគុណច្រើន សូមជម្រាបលា។

**ប្រធានអង្គជំនុំៈ**

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី វីឆាង ឌុងម៉ាន។ សូមអញ្ជើញបាទ!

**លោក ឌេល លីសាក់ៈ**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់**

**សៈ** លោក ឌុងម៉ាន ខ្ញុំឈ្មោះ ឌេល លីសាក់។ ខ្ញុំជាសហព្រះរាជអាជ្ញារងអន្តរជាតិ។ ខ្ញុំនឹងសួរ

សំណួរមួយចំនួននៅថ្ងៃនេះ។

**លោក វីឆាដ ឌុដម៉ាន៖**

**ឆ៖** ជម្រាបសួរ។

**ស៖** កាលពីម្សិលមិញ មេធាវីការពារក្ដី នួន ជា បានសួរលោកអំពីការចាប់ខ្លួននិងការឃុំខ្លួនរបស់លោកនៅវៀតណាម ឬនៅកម្ពុជាដោយកងទ័ពវៀតណាមនៅក្នុងទសវត្សរ៍៧០។ ហើយខ្ញុំចង់អានសម្រង់ចេញពីសៀវភៅរបស់លោកថា "៤០ថ្ងៃជាមួយនឹងខ្មាំង" ដែលមាននៅក្នុងសំណុំរឿង គឺឯកសារ E338.17 នៅត្រង់ S00023188-89 គឺថាយើងមានERN តែជាភាសាអង់គ្លេសទេ។ នៅក្នុងសៀវភៅនេះ លោកសរសេរថា លោកត្រូវបានគេប្រព្រឹត្តយ៉ាងល្អនៅថ្ងៃដំបូង។ លោកត្រូវបានគេប្រព្រឹត្តមកលើរូបលោកគំរោះគំរើយ គឺថាដោយខាងកម្ពុជានេះប្អូនដង។ ហើយការនេះគឺធ្វើឡើងដោយកងទ័ពរំដោះជាតិ ដែលបានធានាដល់សុវត្ថិភាពរបស់លោក ដោយសារពេលហ្នឹង គេយល់ឃើញថា លោកគឺជាអ្នកសារព័ត៌មានអន្តរជាតិ។ នៅពេលដែលលោក -- គេនិយាយថា លោកត្រូវបានអាជ្ញាធរកម្ពុជាប្រព្រឹត្តយ៉ាងអាក្រក់មកលើរូបលោកនោះ តើអាជ្ញាធរមួយណា គេមានកាតព្វកិច្ចម៉េច?

[០៩:២៨:៤០]

**ឆ៖** ខ្ញុំនឹកអត់ឃើញទេលោក។

**ស៖** នៅពេលថា លោកនិយាយសំដៅទៅលើកងទ័ពរំដោះដែលបានធ្វើអន្តរាគមន៍និងការពាររូបលោក លោកចាំបានទេ និយាយ -- ពេលលោកនិយាយថា កងទ័ពរំដោះនេះ តើលោកសំដៅទៅខាងណាដែលថា មកជួយធ្វើអន្តរាគមន៍ ហើយនិងការពារលោកនោះ ?

**ឆ៖** ខ្ញុំអត់ចាំទេ លោកសហព្រះរាជអាជ្ញារង។

**ស៖** ខ្ញុំសូមចូលទៅប្រធានបទមួយផ្សេងទៀតលោក ឌុដម៉ាន។ ខ្ញុំចង់សួរសំណួរលោកមួយចំនួន អំពីបញ្ហាដែលបានលើកឡើងកាលពីម្សិលមិញគឺនិយាយពីឧបសគ្គ ឬក៏ថាការកម្រិត ដែលលោកបានប្រឈមមុខក្នុងនាមលោកជាអ្នកសារព័ត៌មាន ក្នុងការស្វែងរកព័ត៌មានពីកម្ពុជាប្រជាធិបតេយ្យនៅក្នុងខែធ្នូ ឆ្នាំ១៩៧៨។ កាលពីម្សិលមិញ លោក កូប៉េ ដែលជាមេធាវីការពារក្ដី នួន ជា បានអានសម្រង់ចេញពីអត្ថបទរបស់លោកគឺ E3390 គឺវានិយាយអំពីដំណើរទស្សនកិច្ច "គឺមានការកម្រិតជាមួយនឹងការសន្ទនាជាមួយប្រជាជនកម្ពុជាជាធម្មតា ហើយយើងមិនមានឱកាសនិយាយជាមួយអ្នកណាបានទេលើកលែងតែមេដឹកនាំកំពូលពីរបីនាក់តែប៉ុណ្ណោះ"។ បញ្ចប់ការដកស្រង់។ លោកប្រើពាក្យដដែលកាល

ពីម្សិលមិញនោះ នៅពេលដែលលោកប្រាប់ទៅមេធាវីការពារក្ដីថា វាជាដំណើរទស្សនកិច្ចមួយដែលលោកថាលោកមិនសប្បាយចិត្តទេ ដំណើរទស្សនកិច្ចនេះ។ សូមលោកជួយជម្រាបជូនអង្គជំនុំជម្រះមើលថា ហេតុអ្វីបានជាលោកចាត់ទុកថា ដំណើរទស្សនកិច្ចជាដំណើរទស្សនកិច្ចដែលគេរៀបចំឡើង ហើយក្នុងឋានៈលោកជាអ្នកសារព័ត៌មាន លោកមានអារម្មណ៍មិនពេញចិត្តនោះ? សូមលោកជម្រាបជូនអង្គជំនុំជម្រះផង។ ហេតុអ្វី?

[០៨:៣១:០២]

**ឆ៖** ក្នុងនាមជាអ្នកកាសែត ខ្ញុំចង់សំណួរជាច្រើន ចង់បានចម្លើយ ប៉ុន្តែយើងនៅពេលនោះមិនអាចធ្វើយ៉ាងដូច្នេះបានទេ។ ឥឡូវនេះខ្ញុំចាំមិនបានអស់ទេ ដោយសារព្រឹត្តិការណ៍នេះវាជិត -- វាជាព្រឹត្តិការណ៍នេះ វា៤០ឆ្នាំមកហើយ។ ថាប៉ុន្តែសម្រាប់សៀវភៅរបស់ខ្ញុំហ្នឹង វា -- ខ្ញុំមានអារម្មណ៍មួយគឺថាស្ពាក់ស្ពើរ។

**ស៖** សូមអរគុណ។ ឥឡូវហ្នឹងខ្ញុំសូមបង្ហាញលោកនូវឯកសារ E3/1156 នេះជារបាយការណ៍ដែលនៅសេសសល់ពីរបបកម្ពុជាប្រជាធិបតេយ្យ ដែលនិយាយអំពីសំណើសុំឱ្យ ថាទោះបីជាបកប្រែថា "លីតម៉ាន" មិនមែនបកថា "ឌុដម៉ាន" ក៏ដោយ ក៏ប៉ុន្តែមានគឺសំណើសុំពី អេលីហ្សាបេត បេកយ័រ, ខាដវែល និងលោក ដែលកម្មាភិបាលម្នាក់ឈ្មោះ នី កន បានសរសេរ។ ហើយមានសំណើទី៥ ពីខាងលោកមកនៅក្នុងបញ្ជីហ្នឹង ខ្ញុំសូមដកស្រង់៖ "ដើម្បីជួបជាមួយមេដឹកនាំដូចជា នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី អៀង សារី, ឧបនាយករដ្ឋមន្ត្រី សុន សេន, អៀង ធីរិទ្ធ, ខៀវ ប៉ុណ្ណារី, បងន្ទួន និងសម្ដេច សីហនុ"។ បញ្ចប់ការដកស្រង់។ ខ្ញុំយល់ថា វាយូរយារណាស់មកហើយ ក៏ប៉ុន្តែតើលោកចាំទេដែលលោកជួបមនុស្សម្នាក់មកពីក្រសួងការបរទេសឈ្មោះ កន លោកចាំទេ?

**ឆ៖** ខ្ញុំអត់ចាំទេលោក។

[០៨:៣៣:១០]

**ស៖** ខ្ញុំសូមអានជូនលោកស្ដាប់បន្តិច អ្វីដែលលោកបានសរសេរទាក់ទងទៅនឹងសំណើរបស់លោក សុំធ្វើការសម្ភាសមន្ត្រីរដ្ឋាភិបាល។ នេះគឺអត្ថបទដែលមានចំណងជើងថា "ការគ្រប់គ្រងដោយភាពសម្ងាត់" គឺឯកសារ E3/3290 ដែលមាន ERN ភាសាអង់គ្លេស 00419211, ERN ជាភាសាខ្មែរ 01070714-15។ នៅត្រង់នេះលោកនិយាយថា៖ "ក្រៅពីការស្នើសុំម្ដងហើយម្ដងទៀត មានតែមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ដែលត្រូវបានអនុញ្ញាតឱ្យជួប នេះគឺជួបជាមួយ ប៉ុល ពត និង អៀង សារី តែ

ប៉ុណ្ណោះ"។ ហើយលោកក៏បាននិយាយផងដែរថា សូមដកស្រង់៖ "ខ្ញុំបានសុំជួបជាមួយនឹងមន្ត្រីដែលខ្ញុំស្គាល់ ប្រហែលជាសរុបទៅ១០នាក់ រួមមាន បងប្អូនស្រីពីរនាក់ដែលទទួលការអប់រំពីស្រុកបារាំង ដែលរៀបការជាមួយនឹង ប៉ុល ពត ហើយនិង អៀង សារី ហើយចង់ដឹងអំពីតួនាទីសំខាន់របស់ពួកគាត់។ ហើយខ្ញុំបានស្នើសុំជួបជាមួយនឹងអតីតប្រធានរដ្ឋ សម្តេច នរោត្តម សីហនុ ប្រមុខរដ្ឋ ហើយមន្ត្រីទាំងអស់គេបាននិយាយថា គេបានបដិសេធសំណើមិនឲ្យជួបអ្នកទាំងអស់នេះទេ" បញ្ចប់ការដកស្រង់។ "ហើយមិនឲ្យជួបសម្តេច សីហនុ ទេ" បញ្ចប់ការដកស្រង់។ សំណួររបស់ខ្ញុំសួរថាលោកចាំថា លោកដែលផ្តល់ហេតុផល ហេតុណាមួយហេតុអ្វីបានជាលោកមិនអាចជួបជាមួយនឹងមន្ត្រីរដ្ឋាភិបាល ឬក៏ថ្នាក់ដឹកនាំរដ្ឋាភិបាលដូចជា នួន ជា, សុន សេន ហើយនិងប្រពន្ធរបស់ អៀង សារី ហើយនិង ប៉ុល ពត គឺឈ្មោះ អៀង ធីរិទ្ធ និង ខៀវ ប៉ុណ្ណារី? តើលោកមានផ្តល់ហេតុ -- គេមានផ្តល់ហេតុផលអ្វីថាហេតុអ្វីបានជាមិនជួបអ្នកទាំងនេះបានទេ?

**ធ៖** ខ្ញុំអត់ចាំទេ ប្រហែលជាខ្ញុំបានសរសេរចំណុចនេះ។ មិនដឹងគេផ្តល់ហេតុផលយ៉ាងម៉េចទេនៅពេលហ្នឹង ប៉ុន្តែដល់ពេលខ្ញុំពិនិត្យមើលសំណេររបស់ខ្ញុំឡើងវិញ នឹកអត់ឃើញពីរឿងហេតុផលអ្វីទេលោក។

**ស៖** នៅពេលដែលលោកមកទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យនៅភ្នំពេញ ដែលសម្តេច នរោត្តម សីហនុ គឺថាពេលនោះគឺព្រះអង្គនៅគង់នៅក្នុងព្រះរាជវាំង។

**ធ៖** ខ្ញុំអត់មាន -- អត់មាននរណាប្រាប់ខ្ញុំថា ព្រះអង្គនៅក្នុងព្រះរាជវាំងនោះទេ។

**ស៖** តើលោកធ្លាប់ជួបជាមួយនឹង សីហនុ ទេ ពីមុននៅក្នុងប្រទេសចិន?

**ធ៖** គឺថា ខ្ញុំអត់ដែលបានជួបព្រះអង្គទេ។

[០៨:៣៦:០៥]

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅដល់អត្ថបទមួយទៀត ដែលលោកបានសរសេរមានចំណងជើងថា "ការគោរពតាមបញ្ញាមិនអាច -- គឺថាការគោរពតាមបញ្ញាគឺត្រូវតែអាចរស់រានមានជីវិតនៅក្នុងប្រទេសកម្ពុជា"។ ឯកសារ E338.19 នៅក្នុងអត្ថបទនោះនិយាយអំពីការទៅមើលសហករណ៍លាយបូរ នៅក្នុងខេត្តតាកែវ។ នៅពេលដែលលោកនៅទីនោះ លោកត្រូវបានគេប្រាប់ថា សហករណ៍ហ្នឹងគឺមានអ្នកមកពីភ្នំពេញរស់នៅជាមួយដែរ។ ប៉ុន្តែលោកបានសរសេរថា ខ្ញុំសូមដកស្រង់៖ "នៅពេលណា យើងស្នើសុំនិយាយជាមួយអ្នកទាំងនោះ គេតែងតែនាំយើងទៅកាន់វាលស្រែ ទៅមើលការច្រូតកាត់"។ ហើយលោក

បាននិយាយទៅកាន់ម្នាក់ឈ្មោះ នេត យ៉ាន ប៉ុន្តែលោកបានរៀបរាប់អំពីកាលៈទេសៈ អំពីកិច្ចសម្ភាសន៍នេះដូចតទៅ សូមដកស្រង់៖ "មតិយោបល់របស់ យ៉ាន គឺថាវាមិនដូចគ្នានោះទេ គាត់ត្រូវបានសម្ភាសនៅក្នុងរោងបាយមួយជាមួយរដ្ឋាភិបាលមកភ្នំពេញ ដែលជាអ្នកធ្វើការបកប្រែ ហើយនិងកម្មាភិបាលដទៃទៀត មន្ត្រី និងកម្មាភិបាលដទៃទៀត អង្គុយស្តាប់"។ បញ្ចប់ការដកស្រង់។

សំណួររបស់ខ្ញុំគឺយ៉ាងដូច្នេះថា តើមានអ្នកណាម្នាក់នៅក្នុងក្រុមរបស់លោក គឺមានលោក, អេលីហ្សាបេត បេកយ័រ ហើយនិង ម៉ាល់ខូម ខាដវែល ចេះស្តាប់ខ្មែរបានស្ទាត់ជំនាញ ដើម្បីឲ្យយល់ថាប្រជាជនកំពុងនិយាយអ្វីមកកាន់រូបលោកទេ? ឬក៏លោកសំអាងតែទៅលើតែមន្ត្រីមកពីក្រសួងការបរទេស ដើម្បីបកប្រែជូនលោកនៅក្នុងកិច្ចសម្ភាសន៍នេះ?

[០៩:៣៨:០៧]

**ឆ៖** ខ្ញុំមិនចាំថា អ្នកនោះជាអ្នកណាទេ អ្នកដែលប្រាប់ខ្ញុំនុ៎ងជាអ្នកណាទេ ខ្ញុំអត់ចាំទេ។

**ស៖** សំណួររបស់ខ្ញុំលោក ឌុដម៉ាន គឺ តើលោកមានអ្នកបកប្រែផ្ទាល់របស់លោកទេ ឬក៏ត្រូវតែលោកទៅតែពឹងពាក់ទៅលើមន្ត្រីមកពីក្រសួងការបរទេស ដើម្បីបកប្រែជូនលោកនៅពេលលោកធ្វើការសម្ភាស?

**ឆ៖** ខ្ញុំនឹកមិនឃើញថា ខ្ញុំមានអ្នកបកប្រែផ្ទាល់ខ្លួនឬក៏អត់នោះទេ។

**ស៖** ខ្ញុំចាំថារយៈពេលនេះ វាយូរយារណាស់មកហើយ។ នៅពេលដែលលោកនៅសហករណ៍លាយបូរក្នុងខេត្តតាកែវ ហើយស្រុកដែលលាយបូរហ្នឹងជាចម្រុះនោះគឺថា ស្រុកត្រាំកក់។ លោកចាំថាមានកម្មាភិបាលថ្នាក់មូលដ្ឋាននៅទីនោះបានជួបជាមួយលោកទេ?

**ឆ៖** ខ្ញុំនឹកអំពីការជួបប្រជុំនេះមិនឃើញទេលោក។

**ស៖** នៅក្នុងអត្ថបទខែសីហា ឆ្នាំ១៩៨០ ដែលលោកបានសរសេរ គឺឯកសារ E307/5.2.16 ក្រៅពីការដែលលោកបានឃើញ និងបានស្តាប់ លោកបានសរសេរដូចតទៅ សូមដកស្រង់៖ "នៅភ្នំពេញ ហើយនិងដំណើរទស្សនកិច្ចតាមរថយន្ត១០០០ម៉ាយល៍ ខ្ញុំឃើញអំពីភាពឃោរឃៅ"។ តើលោកអាចរៀបរាប់ជូនតុលាការ ជាទូទៅបានទេ តើលោកបានឃើញអ្វីជាទូទៅ នៅក្នុងដំណើរទស្សនកិច្ចរបស់លោកដែលថាវាជាភស្តុតាងគួរឲ្យរន្ធត់ស្តីអំពីភាពឃោរឃៅនេះ។ បញ្ចប់ការដកស្រង់។

[០៩:៤០:៣១]

**ឆ៖** ខ្ញុំមិនចាំថាហេតុអ្វីបានខ្ញុំសរសេរយ៉ាងដូច្នេះ ឬក៏និយាយពាក្យនេះទេ។ ខ្ញុំនឹកមិនឃើញថា

មិនដឹងមានអ្វីដែលនាំឲ្យខ្ញុំសរសេរដល់ពាក្យនេះ ពាក្យ "ឃោរឃៅព្រៃផ្សៃនេះ"។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅប្រធានបទមួយទៀតដែលលោកបានលើកឡើងកាលពីម្សិលមិញ។ លោកមានបំណងចង់ទទួលបាននូវព័ត៌មានពាក់ព័ន្ធទៅនឹងរបបអាហារ ហើយនិងជីវភាពរបស់ប្រជាជននៅក្នុងប្រទេសកម្ពុជា។ លោកសរសេរអត្ថបទមួយ នៅថ្ងៃទី២៨ ខែធ្នូ ១៩៧៨ ដែលមានចំណងជើងថា "តើកម្ពុជាកំពុងតែអត់ឃ្លានឬក៏អត់?" គឺឯកសារ E305/12.58។ នៅក្នុងរបាយការណ៍នេះ លោកបានសរសេរថា លោកឃើញថា មិនមានភស្តុតាងអំពីភាពអត់ឃ្លាននោះទេ ហើយនិងផលិតផលស្រូវហាក់ដូចជាមានការកើនឡើង ទិន្នផលស្រូវ ប៉ុន្តែលោកក៏បានផ្តល់នូវគុណវុឌ្ឍិចំពោះចម្លើយរបស់លោក។ ខ្ញុំសូមដកស្រង់ "នៅក្នុងសេចក្តីសន្និដ្ឋាននេះ គឺថាវាជាបណ្តោះអាសន្នសិនទេ ដោយសាររដ្ឋាភិបាលបដិសេធមិនឲ្យយើង ឬក៏អ្នកជំនាញខាងផ្នែកទិន្នផល ឬពាណិជ្ជកម្មនេះទេ។ យើងបានធ្វើសំណើសុំម្តងហើយម្តងទៀត ដើម្បីជួបជាមួយនឹងអ្នករាយការណ៍ជនជាតិអាមេរិកាំងម្នាក់ ដើម្បីទៅពិនិត្យមើលមន្ទីរពេទ្យ ឬក៏គ្លីនិកតូចៗ ដែលថាត្រូវបានប្រតិបត្តិការនៅទូទាំងប្រទេស។ ហើយយើងក៏មិនអនុញ្ញាតឲ្យធ្វើការសម្ភាសជាមួយនឹងអាជ្ញាធរផ្នែកខាងសុខាភិបាលណាម្នាក់ដែរ"។ បញ្ចប់ការដកស្រង់។

សូមលោកជម្រាបជូនអង្គជំនុំជម្រះ ហេតុអ្វីបានជាសារៈសំខាន់សម្រាប់លោក ក្នុងនាមជាអ្នកកាសែត ទៅពិនិត្យមើលមន្ទីរពេទ្យ ឬក៏ទៅនិយាយជាមួយនឹងមន្ត្រីសុខាភិបាលដើម្បីធ្វើការវាយតម្លៃថា តើប្រជាជននោះបានទទួលថ្នាំសង្កូវគ្រប់គ្រាន់ដែរឬក៏អត់ ពីរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ខ្ញុំចង់ស្វែងរកការពិត។

**ស៖** តើលោកចង់ -- លោកសួរអ្វី បើសិនជាលោកគេអនុញ្ញាតឲ្យជួប ឲ្យពិនិត្យមើលមន្ទីរពេទ្យ ឬជាមួយនឹងកម្មាភិបាល ឬក៏មន្ត្រីខាងផ្នែកសុខាភិបាល លោកនឹងសួរសំណួរអ្វីដែរ?

[០៩:៤៣:២៧]

**ឆ៖** ខ្ញុំព្យាយាមគិតទៅដល់ស្ថានភាពហ្នឹង ឥឡូវកំពុងតែនឹកឡើងវិញ។ ខ្ញុំនឹងសួរសំណួរសមស្របមួយចំនួនដើម្បីស្វែងរកការពិត ថាតើសេវាសុខាភិបាលកាលហ្នឹងៗ វាមានសេវាអ្វីខ្លះដែរ។

**ស៖** លោក ឌុដម៉ាន សាក្សីម្នាក់ដែលបានផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះថ្មីៗនេះ គឺបុរសម្នាក់ឈ្មោះ រៀល សន។ រៀល សន នេះ គឺជាអនុប្រធានមន្ទីរពេទ្យស្រុកត្រាំកក់នៅក្នុងខេត្តតាកែវ នៅក្នុងឆ្នាំ១៩៧៦ រហូតដល់ចុងបញ្ចប់នៃរបបខ្មែរក្រហម។ ស្រុកត្រាំកក់ គឺជាស្រុកមួយដែលគ្រប់គ្រងទៅលើសហករណ៍លាយបូរ ឃុំលាយបូរ។ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំនេះ គឺឯកសារយោងនៅត្រង់ម៉ោង

១១:០៨:៥៨ រហូតដល់ ១១:១៣:៣៧ នៅពេលព្រឹក សាក្សីរូបនេះបានផ្ដល់សក្ខីកម្មថា ផ្នែកនៃរបប នោះ គឺរយៈដែលលោកនៅទីនោះ និយាយពីចំនួនប្រជាជនដែលស្លាប់ដោយសារការខ្វះអាហារូបត្ថម្ភ កាន់តែអាក្រក់ៗឡើង ដោយសារប្រជាជនមិនមានចំណីអាហារហូបចុកគ្រប់គ្រាន់។ ហើយមានមនុស្ស ស្លាប់ប្រាំនាក់ ប្រហែលជាប្រាំនាក់រៀងរាល់ថ្ងៃក្នុងមន្ទីរពេទ្យ ដោយសារតែការខ្វះចំណីអាហារ ហើយ ដែលរាងកាយរបស់ពួកគេនោះ គឺឡើងហើម។ មន្ទីរពេទ្យនេះ គឺចម្ងាយតែ១២ម៉ាយល៍ ប្រហែលជា២០ គីឡូម៉ែត្រចេញពីសហករណ៍គំរូ ដែលលោកបានធ្វើទស្សនកិច្ច គឺសហករណ៍លាយបូរ។

សំណួររបស់ខ្ញុំ តើនេះជាប្រភេទព័ត៌មានដែលលោកជាអ្នកជាកាសែតពេញចិត្តចង់បាន បើសិន ណាជាលោកត្រូវបានគេអនុញ្ញាតឲ្យពិនិត្យមន្ទីរពេទ្យ លោកត្រូវទៅមើលអ្នកជំងឺ និយាយទៅកាន់មន្ត្រី សុខាភិបាលដែរឬទេ ក្នុងដំណើរនេះ?

[០៨:៤៥:៣២]

**ឆ៖** ជាការត្រឹមត្រូវហើយ នេះគឺជាអ្វីដែលខ្ញុំចង់ស្វែងយល់ ចង់រកឲ្យវាឃើញ។

**ប្រធានអង្គជំនុំ៖**

លោកៗ!

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំសូមជំទាស់សំណួរចំពោះសំណួរនេះ គឺស្នើសុំឲ្យសាក្សីឆ្លើយស្មានៗ ហើយខ្ញុំថាវាមិនសម ស្របទេ ក្នុងការតាំងសំណួរបែបនេះ។

**លោក ឌេល លីសាក់៖**

ខ្ញុំសូមឆ្លើយតបលោកប្រធាន។ លោក ឌុដម៉ាន គឺថាជាអ្នកសារព័ត៌មានដែលសរសេរអត្ថបទ ដោយផ្ទាល់ទៅលើសំណួរទាំងអស់នេះ។ បើសិនណាជាគាត់ត្រូវបានគេអនុញ្ញាតនោះ គាត់នឹងទៅសួរ សំណួរបែបហ្នឹង ប៉ុន្តែដោយសារតែគេ -- ខ្មែរក្រហមបានបដិសេធ។ នេះ គឺសំណួរនេះសមស្រប។ ខ្ញុំ យល់ថា សមស្របហើយ។

*(សម្រាករយៈពេលខ្លី)*

[០៨:៤៦:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ ករណីនេះអង្គជំនុំជម្រះអនុញ្ញាតឲ្យលោកសហព្រះរាជអាជ្ញាអាចតាំងសំណួរបែបនេះបាន

ពីព្រោះរឿងនេះ គឺជារឿងបំណងរបស់សាក្សីផ្ទាល់នៅក្នុងអំឡុងពេលនោះ ហើយអង្គជំនុំជម្រះក៏ចង់ដឹងអំពីគំនិតនេះដែរ។ ហើយមេធាវី អង្គជំនុំជម្រះបានអនុគ្រោះនូវការតាំងសំណួរដេញដោលរបស់លោកចំពោះសាក្សី រីឆាដ ឌុដម៉ាន ច្រើនដែរ មកហើយកាលពីម្សិលមិញ។

សូមអញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិ!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** គឺសូមលោកឆ្លើយម្តងទៀតទៅនឹងសំណួររបស់ខ្ញុំអម្បាញ់មិញ។

**លោក រីឆាដ ឌុដម៉ាន៖**

**ឆ៖** ខ្ញុំសូមឲ្យលោកសួរសំណួរឡើងវិញ។

**ស៖** សំណួរសួរថា តើព័ត៌មានដែលខ្ញុំបានអានជូនលោកជាប្រភេទព័ត៌មានដែលលោកចង់បានឬក៏អត់នេះ បើសិនណាជាលោកត្រូវបានអនុញ្ញាតឲ្យទៅពិនិត្យមើលមន្ទីរពេទ្យ ជួបអ្នកជំងឺ និងសម្ភាសមន្ត្រីសុខាភិបាលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ពិតហើយ ខ្ញុំនឹងសួរសំណួរបែបនេះ។

[០៨:៤៨:១៣]

**ស៖** តើវាត្រឹមត្រូវទេទាក់ទងទៅនឹងបញ្ហាការផ្គត់ផ្គង់របបអាហារ ស្ថានភាពការងារ សុខភាពរបស់ប្រជាជន និងចំណុចដទៃៗទៀតនូវអ្វីដែលលោកបានឃើញក្នុងពេលធ្វើដំណើរទស្សនកិច្ច? តើមន្ត្រីរបស់ខ្មែរក្រហម ឬកម្មាភិបាលខ្មែរក្រហមមិនចង់ឲ្យលោកឃើញ គឺដោយសារតែបញ្ហាអស់នេះ ឬក៏យ៉ាងម៉េចលោក?

**ឆ៖** ខ្ញុំថា វាត្រឹមត្រូវហើយ។

**ស៖** តើលោកនឹងមានយោបល់ដូចម្តេចដែរ? ខ្ញុំសូមសួររបៀបនេះវិញ តើលោកមានមធ្យោ-បាយណាមួយដើម្បីផ្ទៀងផ្ទាត់ថា តើសហករណ៍ ហើយនិងការដ្ឋានការងារដែលគេជូនលោកនៅទុំងគឺវាតំណាងឲ្យជីវិតប្រជាជនកម្ពុជាទូទៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** ខ្ញុំមិនច្បាស់ទេថាតើកន្លែងដែលគេនាំឲ្យទៅមើលវាតំណាងឲ្យទាំងមូល ឬក៏អត់ទេ។ ខ្ញុំគិតឃើញថា គេបង្ហាញតែអ្វីដែលល្អៗ។

**ស៖** នៅក្នុងអត្ថបទដដែល ដែលខ្ញុំទើបតែដកស្រង់អម្បាញ់មិញមានចំណងជើងថា“តើប្រទេសកម្ពុជាកំពុងតែមានភាពអត់ឃ្លានឬអត់?” គឺឯកសារ E305/12.58 លោក -- សូមដកស្រង់ “សូម្បីតែ

ទូរលេខសំខាន់ៗអំពីផលស្រូវ សុខភាព ហើយនិងអាហារូបត្ថម្ភនោះ គឺនឹងមិនមានបង្ហាញអ្វីអំពីតម្លៃជាមនុស្សនោះទេ ហើយនេះរួមមានទាំងពីមានការបង្ខិតបង្ខំ ហើយនិងការជម្លៀសចេញប្រជាជនពីទីក្រុងភ្នំពេញដោយបង្ខំ ហើយការផ្តល់ការយកចិត្តទុកដាក់ទៅលើកសិកម្ម ហើយគឺថាមិនមាន នាំឲ្យមិនមានសេរីភាពក្នុងការរៀនសូត្រ អាន សេរីភាពធ្វើដំណើរ ឬការអនុវត្តសាសនានោះទេ”។ បញ្ចប់ការដកស្រង់។ សូមលោកជម្រាបជូនតុលាការថា ហេតុអ្វីបានលោកថា ការពង្រីកទិន្នផលកសិកម្មនេះ គឺធ្វើឲ្យប៉ះពាល់សិទ្ធិជាមូលដ្ឋានរបស់ប្រជាជន?

[០៨:៥០:៤៣]

**ឆ៖** ខ្ញុំនឹកមិនឃើញទេ មិនដឹងជាហេតុអ្វីបានជានាំឲ្យខ្ញុំសរសេរឃ្លានេះទេ។

**ស៖** លោកក៏បានសរសេរនៅក្នុងអត្ថបទនោះដែលថា នៅក្នុងអំឡុងដំណើរទស្សនកិច្ចកម្ពុជា-ភិបាលបានបង្ហាញនូវទំនប់ប្រឡាយមួយចំនួន រួមទាំងអ្វីដែលលោកបានដកស្រង់ថា មានការសាងសង់ទំនប់ធំៗបី ដែលមានកម្មករធ្វើការរាប់ពាន់នាក់ប្រើប្រាស់ គឺថាធ្វើការដោយដៃទទេ។ លោក ឌុដម៉ាន លោកចាំទេ លោកចាំអំពីទំនប់ទាំងនេះទេ? ហើយបើសិនជាចាំនោះ សូមលោកជម្រាបជូនតុលាការអំពីការចងចាំរបស់លោក និងចំណាប់អារម្មណ៍របស់លោកអំពីទំនប់ទាំងនុ៎ង។ តើហេតុអ្វីបានជាគេឲ្យលើកទំនប់អ៊ីចឹង គឺថាប្រើតែកម្លាំងបាយ និងដៃទទេ?

**ឆ៖** ខ្ញុំមិនការចងចាំឲ្យបានល្អទេក្រោយពីរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ខ្ញុំបានសរសេរតែអ្វីដែលខ្ញុំបានឃើញ ហើយខ្ញុំសរសេរតែអ្វីដែលខ្ញុំមានព័ត៌មានដែលនាំឲ្យខ្ញុំសរសេរ ប៉ុន្តែ ខ្ញុំមិនអាចពន្យល់អ្វីឲ្យលើសពីនេះបានទេ។

**ស៖** ខ្ញុំសុំសួរសំណួរមួយទៀតទៅលើប្រធានបទនេះ។ ខ្ញុំសុំយោងទៅអត្ថបទមួយផ្សេងគឺមានចំណងជើងថា “សហករណ៍” គឺឯកសារ E305/12.54 ត្រង់ ERN ជាភាសាអង់គ្លេស S00014149, ERN ជាភាសាខ្មែរ 01063272។ នៅក្នុងអត្ថបទនេះលោករៀបរាប់អំពីចំណីអាហារដែលគេបានផ្តល់ជូនភ្ញៀវបរទេស ដែលមកធ្វើទស្សនកិច្ច ហើយលោកបាននិយាយដូចតទៅ សុំដកស្រង់៖ “អាហារថ្ងៃត្រង់ និងពេលល្ងាច ជានិច្ចជាកាល ស្ទើរតែមានត្រីអណ្តាតឆ្កែពីរក្បាល ឬធំៗ ឬក៏ត្រីផ្សេងទៀត បង្គា ឬក៏បង្កងមួយចានសំប៉ែតធំ និងមាន់។ បើមិនអ៊ីចឹងទេ ក៏សាច់គោដុំធំៗ សាច់ជ្រូកដុំធំៗរួមជាមួយនឹងបាយខ្មែរមួយឆ្នាំងធំ។ បន្លែមានត្រសក់ចិត និងស៊ុតស្ងោរ ជាធម្មតាភេសជ្ជៈគឺស្រាបៀរចិន”។ បញ្ចប់ការដកស្រង់។ តើលោកចាំទេ ដែលលោក តើលោកបានទទួលការផ្តល់ផ្គត់ផ្គង់ចំណីអាហារបែបនេះទេ

ដូចដែលលោកបានរៀបរាប់នេះ? លោក ឌុងម៉ាន លោកឮខ្ញុំសួរដែរ?

[០៨:៥៤:០៣]

**ឆ៖** ខ្ញុំឮ។ ខ្ញុំមិនចាំថាតើខ្ញុំបានទទួលអាហារបែបនេះនៅកន្លែងណាទេនេះ។ ខ្ញុំកំពុងតែមានការភ្ញាក់ផ្អើលដែរ ដែលខ្ញុំសរសេរចំណុចនេះ។

**សៈ** ខ្ញុំចង់សួរបញ្ជាក់ តើលោកគិតថាលោកបានកត់សម្គាល់ឃើញថា ប្រជាជនកម្ពុជាសាមញ្ញទូទៅនោះ បានទទួលរបបអាហារដូចលោករៀបរាប់ដែលគេឲ្យលោកហូបនេះដែរទេ?

**ឆ៖** ខ្ញុំប្រាកដណាស់ថាពួកគេមិនអាចទទួលអាហារបានបែបនេះទេ។

**សៈ** ឥឡូវនេះ ខ្ញុំសុំចូលទៅប្រធានបទបន្ទាប់មួយទៀតគឺ ការប្រព្រឹត្តមកលើអ្នកប្រឆាំងខាងនយោបាយ ឬក៏ខ្មាំងខាងនយោបាយនៅក្នុងរបបខ្មែរក្រហម។ នៅក្នុងកថាខណ្ឌដំបូងនៅក្នុងអត្ថបទមួយចុះថ្ងៃទី២៦ ខែធ្នូ ១៩៧៨ អត្ថបទមានចំណងជើងថា "គឺត្រូវតែអនុវត្តតាម បើអនុវត្តតាមគឺថានឹងមានជីវិតរស់"។ គឺជាឯកសារមួយដែលលោកបានសរសេរគឺឯកសារ E338.19 "នៅក្នុងកម្ពុជាប្រជាធិបតេយ្យនេះគឺមិនមានកន្លែងណាមួយសម្រាប់ឲ្យអ្នកណាមានសិទ្ធិអាន សរសេរ ឬក៏គិតដោយឯករាជ្យបាននោះទេ" បញ្ចប់ការដកស្រង់។ ហើយលោកក៏បាននិយាយថា បដិវត្តន៍កម្ពុជាបានធ្វើការឲ្យវាបានឆ្លើយតបទៅនឹងជីវភាពរស់នៅរបស់ប្រជាជន យើងបានស្តាប់បង្គាប់គឺថានៅក្នុងដំណើរទស្សនកិច្ចហ្នឹងវានាំឲ្យលោក -- លោកមាននឹកឃើញថា ហេតុអ្វីបានជាលោកសរសេរចំណុចហ្នឹង?

**ឆ៖** ខ្ញុំនឹកមិនឃើញហេតុអ្វី ដែលមូលហេតុអីដែលនាំឲ្យខ្ញុំសរសេរត្រង់ឃ្លានេះទេ។

[០៨:៥៦:១៩]

**សៈ** នៅក្នុងអត្ថបទដដែលគឺ E338.19 លោកក៏បានសរសេរផងដែរ សូមដកស្រង់ "បដិវត្តន៍កម្ពុជាច្បាស់ណាស់គឺថា គឺជាបដិវត្តន៍មួយដ៏ -- បដិវត្តន៍កម្ពុជាគឺបដិវត្តន៍ជ្រុលនិយមបំផុតនៅក្នុងប្រវត្តិសាស្ត្រសម័យទំនើប និងពិតជាបានបង្ខំឲ្យអតីតអ្នករស់នៅទីក្រុងថ្នាក់លើ និងថ្នាក់កណ្តាល អនុលោមតាមបទដ្ឋានតឹងរ៉ឹងនៃការងារដោយដៃយ៉ាងលំបាក គ្មានការប្រើប្រាស់លុយ គ្មានប្រព័ន្ធផ្ញើសំបុត្រ គ្មានសេវាទូរស័ព្ទ គ្មានសៀវភៅ គ្មានទ្រព្យសម្បត្តិ ជាបុគ្គលគ្មានការអប់រំកម្រិតខ្ពស់ មានបន្តិចបន្តួច ឬក៏គ្មានសាសនា ហើយនិងដែលមិនអាចទទួលយកបាន ឬក៏យ៉ាងហោចណាស់មិនអាចទទួលបានដោយមតិភាគច្រើននៅលើពិភពលោក។ ចលនាសង្គមនៅក្រោមបដិវត្តន៍កម្ពុជាត្រូវបានគ្រប់គ្រងយ៉ាងល្អលើសពីគំរូរបស់ប្រទេសចិន តាមស្មារតីនៃបដិវត្តន៍វប្បធម៌ដ៏អស្ចារ្យ ដូចជាពាក្យស្លោករបស់ចិនថា

ដែលបច្ចុប្បន្នមានការពាក់ព័ន្ធទៅនឹងក្រុមនៃមេដឹកនាំទាំងបួន”។ តើលោកនឹកឃើញទេ ដែលនិយាយថា វាហួសពីបដិវត្តន៍វប្បធម៌របស់ចិន?

**ឆ៖** ខ្ញុំមិនចាំទេ ហេតុអ្វីបានជាខ្ញុំសរសេរបែបលក្ខណៈប្រៀបធៀបនៅត្រង់នេះ។

**ស៖** នៅក្នុងអត្ថបទដដែលនៅត្រង់ ERN គឺឯកសារដដែលហ្នឹងគឺ ERN អង់គ្លេស 00444 938, ខ្មែរ 01070479 លោកនិយាយអំពីរបបរាយការណ៍អំពីការសម្លាប់មន្ត្រី ក៏ដូចជាទាហានរបប លន់ នល់។ ហើយលោកក៏បានសរសេរផងដែរថា តើលោក អៀង សារី បានឆ្លើយតបយ៉ាងដូចម្ដេចទៅនឹងបញ្ហានេះ? ខ្ញុំសូមដកស្រង់៖ “អៀង សារី ដែលជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស ហាក់ដូចជាមិនបានបដិសេធចំពោះការចោទប្រកាន់ទាំងនេះទេ។ ប៉ុន្តែនៅក្នុងកន្លែងខ្លះគាត់និយាយថា ការកាប់សម្លាប់ខ្លះមិនអាចចៀសផុតទេ នៅក្នុងស្ថានភាពដ៏លំបាកលំបិនក្រោយពីពេលសង្គ្រាម។ បក្សកុម្មុយនីស្តកម្ពុជាបានដោះស្រាយបញ្ហា ហើយនិងចៀសវាងកុំឲ្យមានការកាប់សម្លាប់ច្រើនតទៅទៀត”។ បញ្ចប់ -- បន្តការដកស្រង់៖ “ប្រហែលជាលោកមិនជឿនោះទេ ប៉ុន្តែយើងទទួលខុសត្រូវ ហើយយើងបានក្ដាប់ស្ថានការណ៍ក្នុងប្រទេសរបស់យើងយ៉ាងមុតមាំ។ យើងបានអនុវត្តភារកិច្ចរបស់យើងទាំងអស់ ដើម្បីបម្រើដល់សិទ្ធិរបស់ប្រជាជនយើង គឺមិនមែនគោរពតែសិទ្ធិមនុស្សមួយក្រុមនោះទេ” បញ្ចប់ការដកស្រង់។ លោកបានយោង លោកបានលើកឡើងថាលោកត្រូវបានគេអនុញ្ញាតឲ្យសម្ភាស អៀង សារី តើលោកអាចជម្រាបបានទេ ថាតើកិច្ចសម្ភាសន៍ហ្នឹងធ្វើនៅឯណា? ហើយអ្នកណាមានវត្តមាននៅក្នុងកិច្ចសម្ភាសន៍នោះដែរ? សូមលោកជម្រាបជូនអង្គជំនុំជម្រះអំពីកិច្ចសម្ភាសន៍របស់លោកជាមួយ អៀង សារី។

**ឆ៖** ខ្ញុំមិនចាំកិច្ចសម្ភាសន៍នេះទេ លោក។

[០៨:៥៩:៥៩]

**ប្រធានអង្គជំនុំ៖**

អរគុណលោកសហព្រះរាជអាជ្ញារងអន្តរជាតិ។ អរគុណលោក រីឆាដ ឌុដម៉ាន ឥឡូវហ្នឹងដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក១០នាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងប្រាំបួនដប់នាទីនៅម៉ោងនៅកម្ពុជា សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយលោក រីឆាដ ឌុដម៉ាន ខ្ញុំមិនដឹងថា នៅសហរដ្ឋអាមេរិកហ្នឹងត្រូវម៉ោងប៉ុន្មានទេ ប៉ុន្តែយើងសម្រាក១០នាទី ហើយ១០នាទីក្រោយហ្នឹងសូមលោកអញ្ជើញបន្តផ្ដល់សក្ខីកម្មបន្តទៀត។

**លោក វីឆាដ ឌុដម៉ាន៖**

បាទ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ០៩:០១ នាទី ដល់ម៉ោង ០៩:១១ នាទី)*

[០៩:១១:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី វីឆាដ ឌុដម៉ាន។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក ឌុដម៉ាន សូមអរគុណច្រើនដែលលោកបានយល់ព្រមផ្តល់សក្ខីកម្ម។ ខ្ញុំគិតថាវាអស្ចារ្យណាស់ ព្រោះថាលោកអាយុ៩០ឆ្នាំហើយ។ ឥឡូវនេះខ្ញុំនឹងបន្តការសួរសំណួរដោយអាននូវឯកសារមួយចំនួនដែលលោកបានសរសេរ។ ខ្ញុំយល់ណាស់ថា មានព័ត៌មានមួយចំនួនដែលលោកមិនចាំក៏ប៉ុន្តែនេះគឺជាអ្វីដែលលោកបាននិយាយខ្លួនឯង ហើយនិងសរសេរ ហើយជាចំណុចដែលយើងចាប់អារម្មណ៍។ អ្វីដែលយើងចង់សួរនោះគឺ ពាក់ព័ន្ធនឹងអ្វីដែលលោកបាននិយាយ ខ្ញុំសូមបន្ត ប្រហែលជាសំណួររបស់ខ្ញុំអាចនឹងធ្វើឲ្យលោកនឹកឃើញឡើងវិញខ្លះៗ។ មានអត្ថបទមួយដែលលោកសរសេរ ដែលនិយាយថា ខ្មាំងវៀតណាម គឺឯកសារ E3/3290, ជាភាសាអង់គ្លេស 00419207, ជាភាសាខ្មែរ 01070696។ លោកបានសរសេរនៅក្នុងឯកសារនោះថា៖ "ក្នុងអំឡុងពេលធ្វើដំណើរទស្សនកិច្ចនេះកម្មាភិបាលបានរិះគន់កងទ័ពវៀតណាមជាបន្តបន្ទាប់ ដូចអ្វីដែលវិទ្យុភ្នំពេញហៅថាជា ពួកហ្វាស៊ីស

កុម្មុយនីស្តក្លែងក្លាយ ពួកឈ្លានពាន និងជាប្រទេសគុយបាក្នុងតំបន់អាស៊ី ពួកលេបយកទឹកដី និងជាសត្វក្រពើ សត្វរមើលគុណបំផុតដែលមិនស្គាល់ម្ចាស់ ដែលធ្លាប់ផ្តល់ចំណីដល់ខ្លួន។ កម្មាភិបាលក្រសួងការបរទេសម្នាក់ដែលអមដំណើរជាមួយយើងនៅទូទាំងប្រទេស បាននាំយើងទៅកាន់សួនសត្វ និងនៅចំណុចមួយបាននិយាយថា សូមមកមើលអ្នកទោសវៀតណាម។ គាត់បាននាំផ្លូវយើងទៅកាន់រណ្តៅមួយដែលមានក្រពើធំ១៦០ក្បាល។ នៅពេលមួយផ្សេងទៀត កម្មាភិបាលម្នាក់នោះបាននិយាយដោយទឹកមុខមាំថា កម្មាភិបាលកងទ័ពវៀតណាមទាំងអស់សុទ្ធតែមានប្រពន្ធបី ម្នាក់នៅទីក្រុងហាណូយម្នាក់ទៀតសាយហ្គន និងម្នាក់ទៀតនៅសមរភូមិមុខ"។ តើលោកមានចាំអំពីការប្រតិកម្មតបរបស់លោកទេ នៅពេលដែលកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យបាននិយាយបែបនេះចំពោះលោក ពាក់ព័ន្ធនឹងវៀត-ណាមនោះ?

[០៩:១៥:០៩]

**លោក រីឆាដ ឌុដម៉ាន៖**

**ឆ៖** ខ្ញុំជាអ្នកកាសែត។ ខ្ញុំគិតថា ខ្ញុំសរសេរហ្នឹង គឺដើម្បីឲ្យពួកគាត់សប្បាយរីករាយ។

**ស៖** លោក ឌុដម៉ាន ខ្ញុំចង់អានឧទាហរណ៍ពីរបីផ្សេងទៀត នៃការផ្សាយវិទ្យុនៅសម័យកម្ពុជាប្រជាធិបតេយ្យ គឺនៅខែធ្នូ ឆ្នាំ១៩៧៨ ដែលលោកនៅទីនោះ គឺឯកសារ E3/295។ នេះគឺជាឯកសាររបស់ហ្វីប៊ីស ខែធ្នូ ឆ្នាំ១៩៧៨។ ទំព័រគឺ 00169107 ដែលចុះខែធ្នូ ឆ្នាំ១៩៧៨ ដែលសរសេរដូចតទៅ៖ "បើតាមប្រភពនៅវៀតណាម កងទ័ពបានខុង គឺកាចសាហាវ ហ្វាស៊ីស ជាងពួកកងទ័ពធីវគី ទៅទៀត"។ កថាខណ្ឌបន្ទាប់មកទៀត "ដើមខែវិច្ឆិកា ទាហានម្នាក់ដែលមានពាក់ផ្កាយ១" ហើយលក្ខខណ្ឌបន្តមកទៀត "គឺរដ្ឋាភិបាលឡេឌួន បានសុំឲ្យគ្រួសារខាងវៀតណាមខាងត្បូង គឺឲ្យចិញ្ចឹមទាហានមកពីខាងវៀតណាមខាងជើង។ ទាហានទាំងអស់នេះ គឺថាអាចលួចទ្រព្យសម្បត្តិរបស់ប្រជាជនដែលមកទទួលបាន ហើយថែមទាំងរំលោភស្ត្រីជាមេគ្រួសារទៅទៀត គ្រួសារដែលទទួលពួកហ្នឹង។ គឺថាពួកគេប្រព្រឹត្តអំពើឃោរឃៅទៅលើគ្រួសារទាំងអស់នោះ"។

[០៩:១៧:១៤]

ការចុះផ្សាយខែធ្នូ ឆ្នាំ១៩៧៨, ERN 0016915 បានសរសេរដូចតទៅ៖ "ឆ្កែវៀតណាមរបួសនិងស្គមនោះ គឺសុទ្ធតែវីរុស។ សូម្បីតែពួកចៅហ្វាយរបស់វា ដែលជាពួកសូវៀតហ្នឹង ក៏មិនអាចជួយបានដែរ។ ឆ្កែវៀតណាមស្គមស្គាំង កាន់តែស្គមទៅៗ ហើយពួកវានឹងស្លាប់នៅពេលជិតៗនេះ"។ នៅ

ខែធ្នូ ឆ្នាំ១៩៧៨ គឺERN 00163135 មានការផ្សាយអំពីចម្លើយសារភាពរបស់ស្ត្រីវៀតណាមម្នាក់ដែលជាគិញ ដែលបាននិយាយដូចតទៅ -- ចម្លើយសារភាពរបស់ ឡេធី វេញសង របស់ស្ត្រីវៀតណាមដែលចាប់ដោយកងទ័ពបដិវត្តន៍កម្ពុជា នៅក្នុងខេត្តស្វាយរៀង នៅខែតុលា ឆ្នាំ១៩៧៨។ ចម្លើយសារភាពនេះបញ្ជាក់ថា "បនវៀតណាមបានប្រព្រឹត្តអំពើសាហាវឃោរឃៅចំពោះកម្ពុជាក្រោម។ ពួកគេអារ-កទារក ហើយបានចាក់ថ្នាំឱ្យម្តាយស្លាប់ ដែលម្តាយដែលទើបតែសម្រាលកូន"។

លោក ឌុដម៉ាន ខ្ញុំបានអានសម្រង់មួយចំនួននេះជូនទៅលោក។ អ៊ីចឹង ខ្ញុំចង់សួរលោកថាតើនេះជាប្រភេទព័ត៌មានប្រឆាំងនឹងវៀតណាមដែលលោកបានស្តាប់ឮ នៅពេលដែលលោកនៅកម្ពុជាប្រជាធិបតេយ្យ នៅខែធ្នូ ឆ្នាំ១៩៧៨ មែនទេ?

**ឆ៖** ខ្ញុំគិតថា វាជាចំណុចដូចគ្នា។ ខ្ញុំបានស្តាប់ឮពីសម័យនោះ។

[០៩:១៩:២៣]

**ស៖** តើលោកចាំទេ ថាលោកធ្លាប់បានអានរបាយការណ៍របស់ហ្វីប៊ីស ពាក់ព័ន្ធទៅនឹងការផ្សាយរបស់វិទ្យុនៅសម័យកម្ពុជាប្រជាធិបតេយ្យ។ តើលោកចាំទេ ថាតើលោកដឹងអំពីការផ្សព្វផ្សាយនេះ ដោយរបៀបណា?

**ឆ៖** ខ្ញុំអត់ចាំទេ ថាតើខ្ញុំបានមើល បានស្តាប់ការផ្សាយវិទ្យុហ្នឹង ឬក៏អត់ទេ។

**ស៖** នៅក្នុងកថាខណ្ឌ២ដំបូងនៃអត្ថបទ E305/12.54 លោកបានសរសេរថា លោកបានដឹងអំពីសុន្ទរកថារបស់ ប៉ុល ពត នៅខែ -- នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៨ គឺថ្ងៃនោះហើយ ដែលលោកបានជួបជាមួយលោកស្រី បេកយ័រ លោកបានសរសេរថា -- លោកបានរាយការណ៍ថា "ប៉ុល ពត បាននិយាយថា ប្រជាជន៩៥ភាគរយនៅកម្ពុជាប្រជាធិបតេយ្យ គឺសុទ្ធតែជាមនុស្សល្អ។ ពួកគេអាចកសាងខ្លួនបាន ហើយពួកគេកំពុងតែធ្វើការដើម្បីកសាងខ្លួន គឺនៅសល់តែប្រហែលជាមួយភាគរយទៀតតែប៉ុណ្ណោះ"។ តើលោកចាំទេថានេះជាអ្វីដែល ប៉ុល ពត បាននិយាយប្រាប់លោកនៅក្នុងពេលដែលលោកសម្ភាសជាមួយគាត់តទល់គ្នា ឬក៏លោកចាំទេថា លោកទទួលបានចម្លើយលាយលក្ខណ៍អក្សរទៅនឹងសំណួរដែលលោក និងលោកស្រី បេកយ័រ បានផ្ញើទៅនោះ?

**ឆ៖** ខ្ញុំអត់ចាំទេ។ ខ្ញុំមិនដឹងថា តើខ្ញុំទទួលបានព័ត៌មានទាំងនេះ ដោយរបៀបណាទេ។

[០៩:២១:២០]

**ស៖** តើលោកចាំទេថា ប៉ុល ពត បានផ្តល់ព័ត៌មានជូនលោកពាក់ព័ន្ធទៅនឹងរបៀបដែលគាត់

ទទួលបានភាគរយនៃមនុស្សដែលកសាងខ្លួននេះ?

**ឆ៖** ខ្ញុំមិនដឹងទេ លោកព្រះរាជអាជ្ញា។

**ស៖** ឥឡូវនេះ ខ្ញុំនឹងសួរសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងកម្មាភិបាលខ្មែរក្រហម គឺពាក់ព័ន្ធនឹងចំណុចនេះ គេផ្តល់ព័ត៌មានជូនលោក ឬក៏លោកបានសួរសំណួរ។ នៅក្នុងអត្ថបទរបស់លោកនិយាយអំពីការដឹកនាំជាសម្ងាត់ គឺឯកសារ E3/3290, ERN ជាភាសាអង់គ្លេស 00419211, ជាភាសាខ្មែរ 01070714។ លោកបាននិយាយថា “លោក ឱក សុគន្ធ ជាមន្ត្រីក្រសួងការបរទេស បានប្រាប់លោកថា ហ៊ូ នឹម ជាមន្ត្រី -- រដ្ឋមន្ត្រីក្រសួងព័ត៌មាន និង ហ៊ូ យន់ ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គឺកំពុងតែធ្វើការយ៉ាងសកម្មនៅក្នុងរដ្ឋាភិបាល ទោះបីជាមានការជឿជាក់ថា គាត់បាត់ខ្លួន ឬក៏ស្លាប់ក៏ដោយ”។

ខ្ញុំនឹងនិយាយអំពីឯកសារមួយទៀត គឺឯកសារ E333.1។ លោក ឌុដម៉ាន នេះជាឯកសាររបាយការណ៍ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៨ សរសេរដោយមន្ត្រីកម្ពុជាប្រជាធិបតេយ្យ ដែលនិយាយអំពីទស្សនកិច្ចរបស់លោក។ ក្នុងឯកសារនោះ មាននិយាយអំពីផ្នែកមួយដែលមានចំណងជើងថា “សំណើបន្ថែមដោយភ្ញៀវ”, ERN ជាភាសាអង់គ្លេស 01054090, ជាភាសាខ្មែរ 01047239, ជាភាសាបារាំង 01054094។ ខ្ញុំសូមដកស្រង់៖ “សាស្ត្រាចារ្យអង់គ្លេសបានសួរសំណួរពាក់ព័ន្ធទៅនឹងលោក ថៅ សេង និង ភោគ ឆាយ”។ ខ្ញុំយល់ថា ខ្ញុំសួរលោកច្រើន ក៏ប៉ុន្តែលោកចាំទេថា លោក និងលោកស្រី បេកយ័រ និងលោក ខាដវែល បានទទួលចម្លើយទេ នៅពេលដែលលោកសួរអំពីកម្មាភិបាលទាំងអស់ដែលខ្ញុំបានរៀបរាប់ឈ្មោះនេះ?

**ឆ៖** ខ្ញុំមិនចាំទេថា គេឆ្លើយតបឬក៏អត់ទេ។

[០៩:២៤:២៧]

**ស៖** ឯកសារ E3/2285, ERN ជាភាសាខ្មែរ 00009220 ទៅដល់ 23, ជាភាសាអង់គ្លេស 00873450 ទៅដល់ 61។ ឯកសារនេះជាបញ្ជីគុកស-២១ ដែលមានចំណងជើងថា “ឈ្មោះអ្នកទោសត្រូវបានកម្ទេចនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៧”។ បញ្ជីនេះបង្ហាញឈ្មោះអ្នកទោស១២៧នាក់ ដែលត្រូវបានសម្លាប់នៅក្នុងគុកនេះ នៅថ្ងៃនោះ។ អ្នកទោសលេខ១២៣ គឺឈ្មោះ ភោគ ឆាយ។ ឈ្មោះនេះហើយដែល ម៉ាល់ខូម ខាដវែល បានសួរទៅកម្មាភិបាលខ្មែរក្រហម។ ហើយលេខ១២៥គឺ រដ្ឋមន្ត្រីក្រសួងឃោសនាការ ហ៊ូ នឹម គឺជាបុគ្គលម្នាក់ដែលគេប្រាប់លោកថា នៅរស់នៅឡើយនៅកម្ពុជាប្រជាធិប-តេយ្យនៅក្នុងខែធ្នូ ឆ្នាំ១៩៧៨។ លោក ឌុដម៉ាន តើលោកចាំទេថាលោកមានអារម្មណ៍បែបណាពាក់ព័ន្ធ

ទៅនឹងភាពទៀងត្រង់របស់មន្ត្រីកម្ពុជាប្រជាធិបតេយ្យនៅពេលដែលពួកគាត់និយាយអំពីអ្នកទោស និងអ្នកទោសនយោបាយនៅក្នុងប្រទេសនោះ?

**ធ៖** ខ្ញុំអត់ចាំទេ។

**ស៖** នៅក្នុងរបាយការណ៍ដែលខ្ញុំបាននិយាយអម្បាញ់មិញនេះ គឺឯកសារលេខ E3/1156។ មានបញ្ជីសំណើដែលលោកបានធ្វើក្នុងក្របខ័ណ្ឌនៃការធ្វើដំណើររបស់លោក គឺសំណើទី៧នោះគឺថា ជារបស់លោកដែលបញ្ជាក់ថាលោកបានចោទបដិវត្តន៍ថាបានសម្លាប់ប្រជាជន ហើយលោកបានស្នើសុំទៅមើលអ្នកទោសនយោបាយ ហើយលោកក៏ចង់ដឹងថា តើបដិវត្តន៍ធ្វើអ្វីខ្លះពាក់ព័ន្ធទៅនឹងអ្នកប្រឆាំងនឹងនយោបាយ។ តើលោកបានទទួលចម្លើយបែបណាទៅនឹងសំណើរបស់លោកដែលស្នើសុំទៅមើលគុកនោះ?

**ធ៖** ខ្ញុំអត់ចាំអំពីចម្លើយដែលខ្ញុំទទួលបាននៅពេលនោះទេ។

**ស៖** តើលោកមានបានទៅមើលគុក ឬមន្ទីរអប់រំកែប្រែទេនៅក្នុងសម័យកម្ពុជាធិបតេយ្យ?

**ធ៖** ខ្ញុំអត់ចាំទេ។

[០៩:២៧:១០]

**ស៖** តើលោកមានឱកាសក្នុងការទៅទស្សនកិច្ចស-២១ ឬគុកទួលស្លែងនៅភ្នំពេញដែរឬទេ? តើលោកដឹងទេថា គុកនេះស្ថិតនៅចម្ងាយតែមួយទៅ២គីឡូម៉ែត្រពីផ្ទះភ្ញៀវដែលគេទទួលលោកនៅពេលដែលលោកមកកម្ពុជានៅខែធ្នូ ឆ្នាំ១៩៧៨?

**ធ៖** ខ្ញុំអត់ចាំថាខ្ញុំបានទៅមើលគុកនោះទេ។

**ស៖** លោក លោកស្រីចៅក្រម បើតាមឯកសារ E3/342 ដែលជាបញ្ជីអ្នកទោស ស-២១ ដែលពិនិត្យមើលឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា និងបើតាមឯកសារ E3/1651 ដែលជាឯកសារសួរចម្លើយនៅស-២១ ខែធ្នូ ឆ្នាំ១៩៧៨ គឺមានអ្នកទោសថ្មីសរុប៣៥នាក់ ដែលត្រូវបានបញ្ជូនទៅស-២១ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៧៨ គឺជាថ្ងៃដំបូងតែម្តងដែលលោកនៅភ្នំពេញនៅក្នុងចំណោមអ្នកទោសទាំងអស់នោះ ស្ត្រីកម្មាភិបាលបីនាក់ត្រូវបានចាប់ខ្លួនពីក្រសួងការបរទេស និងកម្មាភិបាលវេជ្ជសាស្ត្រប្រាំបីនាក់ ជាពិសេសគឺស្ត្រីម្នាក់ដែលមានអាយុ១៦ឆ្នាំ ដែលធ្វើការនៅមន្ទីរពេទ្យ ផ-៧៥។ ហើយនៅទី១១ ខែធ្នូ ឆ្នាំ១៩៧៨ នៅពេលដែលលោកនៅទីក្រុងភ្នំពេញនោះ ឯកសារមកពីមន្ទីរ ស-២១ បានបញ្ជាក់ថា អ្នកទោស២៨នាក់ត្រូវបានសម្លាប់នៅថ្ងៃនោះ។ នេះគឺជាគុកតែមួយតែប៉ុណ្ណោះ ហើយ

វាពាក់ព័ន្ធទៅនឹងពីរថ្ងៃដំបូងដែលលោកមកទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យ។ តើកម្មាភិបាលក្រសួងការបរទេសដែលអមដំណើរលោកនោះ មានបាននិយាយប្រាប់លោកពាក់ព័ន្ធទៅនឹងចំនួនមនុស្សជាច្រើនដែលត្រូវបានចាប់ខ្លួន និងសម្លាប់ចោលនៅមន្ទីរស-២១ ដែរឬទេ? ឬក៏ពួកគាត់បាននិយាយទេថាកម្មាភិបាលក្រសួងរបស់ពួកគាត់ហ្នឹងត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅមន្ទីរសន្តិសុខ?

[០៩:២៩:៣០]

**ឆ៖** ខ្ញុំមិនចាំថាគេបាននិយាយប្រាប់ខ្ញុំអំពីរឿងនេះទេ។

**ប្រធានអង្គជំនុំ៖**

ឈប់!

**លោក វ៉ិចទ័រ កូប៉េ៖**

ហេតុអីក៏សហព្រះរាជអាជ្ញាសួរលោក ឌុដម៉ាន អំពីរឿងហ្នឹងទាំងអស់ទៅវិញ? ខ្ញុំចង់បញ្ជាក់ជាប្រតិចារឹកថា យើងមានផ្នែកពាក់ព័ន្ធនឹងមន្ទីរស-២១ នៅពេលក្រោយ។ អ៊ីចឹងចាំពេលនុ៎ងទៅចាំសួរពាក់ព័ន្ធនឹងមន្ទីរស-២១ ហើយយើងមកសួរឥឡូវអំពីស-២១ នោះវាជារឿងមិនសមស្របនោះទេ។ ខ្ញុំជំទាស់។

**លោក ឌេល លីសាក់៖**

លោកប្រធាន សាក្សីនេះបានសរសេរ ពាក់ព័ន្ធទៅនឹងអ្នកទោសនយោបាយ។ គាត់បានចង់ដឹងបានចង់សួរសំណួរ ហើយគុកនោះស្ថិតនៅចម្ងាយប្រហែល ១គីឡូ ២គីឡូ ពីកន្លែងដែលគាត់ស្នាក់នៅ។ អ៊ីចឹងខ្ញុំសួរគាត់ថាតើគាត់ គេមានរាំងគាត់ឲ្យទៅពិនិត្យមើលគុកហ្នឹងទេ?

[០៩:៣០:៣៥]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣០:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញបន្តសួរទៀតចុះ។ ហើយអង្គជំនុំជម្រះសូមរំឭកដល់ភាគីថា ភាគីអាចតាំងសំណួរដេញដោលចំពោះសាក្សីណាមួយបាន នៅគ្រប់អង្គហេតុទាំងអស់ដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការនៅក្នុងសំណុំរឿង០០២។ ដរាបណាសាក្សីនោះ គឺគាត់មានវ័យចំណាស់ ហើយគាត់ដឹងរឿងហេតុគ្រប់អង្គហេតុទាំងអស់ ឬក៏ច្រើនអង្គហេតុគឺអង្គហេតុដែលគាត់ដឹង គឺអាចតាំងសំណួរពាក់ព័ន្ធបានទាំងអស់

នៅក្នុងអំឡុងពេលដែលសាក្សីរូបនោះមកផ្តល់សក្ខីកម្ម។

**លោក ខេល លីសាក់៖**

**ស៖** លោក ឌុងម៉ាន នៅពេលដែលលោកស្នាក់នៅទីក្រុងភ្នំពេញ តើលោកចាំទេថា លោកនិងលោកស្រី បេកឃ័រ ត្រូវបានគេអនុញ្ញាតឲ្យដើរហើរសេរីនៅក្នុងទីក្រុងទេ?

**លោក វីឆាដ ឌុងម៉ាន៖**

**ឆ៖** ខ្ញុំអត់ចាំច្បាស់អំពីចំណុចហ្នឹងទេ។

**ស៖** ខ្ញុំសូមអានសម្រង់មួយនៃអត្ថបទដែលលោកបានសរសេរ ដើម្បីរំឭកការចងចាំរបស់លោក គឺឯកសារ E3/3290 ERN ជាភាសាអង់គ្លេស 00419207, ERN ជាភាសាខ្មែរ 01070693-94។ លោកបានសរសេរដូចតទៅ៖ "មន្ត្រីខ្មែរក្រហមបានព្រមានយើងថា មិនត្រូវទៅណាមកណាដោយគ្មានការអមពីពួកគេទេ រួមទាំងនៅក្នុងភ្នំពេញផងដែរ ដែលជាទីក្រុងស្ទើរតែគ្មានមនុស្សនៅ។ នៅពេលដែលយើងបានគេចចេញទៅមើលនោះ គឺថាយើងដឹងថា ការព្រមាននេះ គឺគ្រាន់តែជាលេសទេ។ ហើយនៅពេលនោះគឺថា យើងបានចេញទៅមើលនៅទីក្រុង ហើយនៅពេលនោះមានអ្នកយាមម្នាក់ចាប់លោកស្រី បេកឃ័រ ហើយទាញដៃត្រឡប់ទៅវិញ"។ តើលោកចាំទេថា មានអ្វីកើតឡើងនៅទីក្រុងភ្នំពេញនៅពេលដែលលោកបានធ្វើដំណើរទៅណាមកណានោះ?

[០៩:៣៣:០៤]

**ឆ៖** កាលពីម្សិលមិញ គេបាននិយាយពីចំណុចនេះ ប្រាប់ខ្ញុំហើយ។ ខ្ញុំបាន -- ខ្ញុំអាចជម្រាបបានថាខ្ញុំពិបាកហ្នឹងរំឭកឃើញពីអ្វីដែលបានកើតឡើងនៅពេលនោះណាស់។

**ស៖** បាទ កាលពីម្សិលមិញ ភាគីការពារក្តីរបស់ នួន ជា – មេធាវីរបស់លោក នួន ជា បាននិយាយអំពីអត្ថបទមួយដែលលោកបានសរសេរនៅខែសីហា ឆ្នាំ១៩៩០ នៅក្នុងកាសែតញូវយ៉កថែមស៍។ មេធាវីការពារក្តីបានអានកថាខណ្ឌទី៥ នៃអត្ថបទនេះ ដែលមានសរសេរថា៖ "ត្រូវតែប្រយ័ត្នប្រយែងទាក់ទងទៅនឹងអ្វីដែលយើងយល់ឃើញថា ខ្មែរក្រហម ប៉ុល ពត អីហ្នឹងសុទ្ធតែជាអ្នកជ្រុលនិយមហើយប្រព្រឹត្តអំពើប្រល័យពូជសាសន៍ជាដើម"។ នៅផ្នែកក្រោយ ចុងគេនៃអត្ថបទហ្នឹង លោកបានសរសេរដូចតទៅនេះ ខ្ញុំសូមអាន៖ "តើទាក់ទងទៅនឹងការសម្លាប់មនុស្ស កន្លែងសម្លាប់មនុស្ស ហើយនិងលលាដ៍ក្បាល គឺថាមានជនរងគ្រោះជាង១០០នាក់ ហើយអីចឹងគឺមានការសម្លាប់មនុស្សទ្រង់ទ្រាយធំ ក៏ប៉ុន្តែមិនមានការបង្ហាញឲ្យឃើញថាមានអំពើប្រល័យពូជសាសន៍នោះទេ។ ដូច្នេះ ខ្ញុំដោយផ្ទាល់

ខ្ញុំគិតថា ប៉ុល ពត មិនមែនជាអ្នកជ្រុលនិយម ក៏ប៉ុន្តែជាអ្នកដឹកនាំបដិវត្តន៍ដែលកំពុងតែជិះលើខ្នងខ្លា។ គឺថា ឧទាហរណ៍ថាមាន ដោយសារតែគាត់គ្រប់គ្រងប្រជាជនល្ងង់ខ្លៅ ហើយក្រ ហើយទទួលការរុករានច្រើន។ អ៊ីចឹងគឺថាត្រូវ ជម្រើសគឺថាទុកឲ្យមនុស្សស្លាប់នៅតាមទីក្រុង ឲ្យអត់អាហារ ឬក៏ឲ្យពួកគេទៅធ្វើការ ដោយបញ្ចេញពលកម្ម។" អ៊ីចឹងខ្ញុំចោទសំណួរលោកមួយចំនួនបន្តពីអត្ថបទនេះ អ៊ីចឹងថា នៅពេលដែលលោកសរសេរអត្ថបទនេះនៅក្នុងឆ្នាំ១៩៩០ តើលោកធ្លាប់បានពិគ្រោះឯកសារនៅមន្ទីរទួលស្លែង នៅភ្នំពេញអីឬទេ? ព្រោះថាឯកសារទាំងអស់នេះបានបង្ហាញថា មានមនុស្ស១២.០០០នាក់ត្រូវបានសម្លាប់នៅក្នុងគុកនេះ។

**ឆ៖** ខ្ញុំមិនមានព័ត៌មានទាំងអស់នេះទេ ខ្ញុំមិនបានពិគ្រោះព័ត៌មានទាំងអស់នេះនោះទេ។

[០៩:៣៥:៥៣]

**ស៖** ម្សិលមិញលោកបាននិយាយថា នៅពេលលោកសរសេរអត្ថបទនេះនៅឆ្នាំ១៩៩០ លោកបានពិគ្រោះប្រភពផ្សេងៗទៀត គឺថាអានឯកសារផ្សេងៗមួយចំនួនដែលនាំឲ្យលោកផ្លាស់ប្តូរគំនិតរបស់ខ្លួនដែលទាក់ទងទៅថា ដែលបង្ហាញថាមានការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ហើយនិងឧក្រិដ្ឋកម្មទ្រង់ទ្រាយធំនៅក្រោមរបបខ្មែរក្រហម។ តើលោកអាចផ្តល់ប្រភពដែលលោកបានពិគ្រោះនេះដែរឬទេ ក្រោយឆ្នាំ១៩៩០ ហើយដែលធ្វើឲ្យលោកផ្លាស់ប្តូរគំនិតនោះ?

**ឆ៖** បាទ ខ្ញុំគិតថាខ្ញុំបានផ្លាស់ប្តូរគំនិតមែន ក៏ប៉ុន្តែខ្ញុំមិនដឹងហេតុអីបានខ្ញុំបានផ្លាស់ប្តូរគំនិតនោះទេ។

**ស៖** យើងបាននិយាយអំពីអត្ថបទមួយដែលលោកបានសរសេរនៅក្នុងឆ្នាំ១៩៧៨ គឺនៅខែធ្នូ ឆ្នាំ១៩៧៨ គឺថាការគោរពបញ្ហាមេដើម្បីរស់រានមានជីវិតនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។ ឯកសារនោះគឺ E338.19 ខ្ញុំសូមដកស្រង់ដូចតទៅនេះ៖ "ការវាយតម្លៃមួយសមស្របបង្ហាញឲ្យឃើញថា កត្តាសំខាន់នៃការស្លាប់ជាច្រើននោះ ទោះបីជាចំនួនប៉ុនណាក៏ដោយបង្ហាញឲ្យឃើញថា ក្នុងរយៈពេល៣ឆ្នាំកន្លះ នៅពេលចុងពេលរបបនេះ ជិតរំលំគឺថាមានការធ្វើការបដិវត្តន៍សង្គមដែលមិនមានអាចប្រៀបផ្ទឹមគ្នាទេ។ ខ្ញុំមិនដឹងថាមេដឹកនាំបានជំរុញឲ្យមានអំពើហិង្សាយ៉ាងនេះនោះទេ ឬយើងពិបាកនិយាយណាស់ត្រង់ចំណុចនេះ"។ លោកសាក្សី តើនៅឆ្នាំ១៩៧៨នោះ តើលោកធ្លាប់បានពិគ្រោះឯកសារទាក់ទងទៅនឹងខ្មែរក្រហមដែរឬទេ? ហើយដោយជាក់លាក់នោះ តើលោកមានចាំថា លោកធ្លាប់បានពិគ្រោះការបោះពុម្ពផ្សាយនៃទស្សនាវដ្តីទង់បដិវត្តដែរឬទេ ដែលជាឯកសារផ្ទៃក្នុង ដែលបែកចែកចាយដោយបក្សដែល

នៅក្របនេះយើងឃើញមានរូបទង់ជាតិ គឺជាទស្សនាវដ្តីដែលផ្ញើទៅកម្មាភិបាលរាល់ខែ? តើលោកធ្លាប់បានពិគ្រោះឯកសាររបៀបនេះដែរឬទេ? ឬក៏ថាកាលដែលលោកមកប្រទេសកម្ពុជានោះ តើខ្មែរក្រហមមានឱ្យលោកពិគ្រោះឯកសាររបៀបនេះទេ?

[០៩:៣៨:៣៩]

**ឆៈ** បាទ ខ្ញុំមិនចាំថាខ្ញុំបានពិគ្រោះឯកសារបែបនេះទេ។

**សៈ** បាទមានសំណួរមួយចំនួនលើកឡើងនៅក្នុងទង់បដិវត្តនេះ ខ្ញុំសូមដកស្រង់ផ្នែកមួយនៃទស្សនាវដ្តីដែលចុះនៅខែមេសា ឆ្នាំ១៩៧៧ គឺឯកសារ E3/742 ហើយខ្ញុំចង់សូមមតិយោបល់ពីលោកលើទស្សនាវដ្តីនេះ។ នេះគឺជាសុន្ទរកថារបស់មេដឹកនាំខ្មែរក្រហម ដែលនិយាយពីផែនការនៅឆ្នាំ១៩៧៧ ERN គឺភាសាអង់គ្លេសគឺ 00478496, ERN ជាភាសាបារាំងគឺ 00499754, ERN ជាភាសាខ្មែរគឺ 00062986។ មានការណែនាំទៅកម្មាភិបាលបក្ស ខ្ញុំសូមដកស្រង់៖ "ទាក់ទងទៅនឹងខ្មាំង សេ.អ៊ី.អា, កា.ហ្សេ.បេ ហើយនិងភ្នាក់ងារយួន ឬខ្មាំងយួននេះ។ អាផ្តែដែលវាចូលមកជួរបក្សបដិវត្តន៍ យើងត្រូវតែបន្តប្រឆាំងពួកវា ហើយនិងប្រថុយយ៉ាងរារាំងកុំឱ្យវាមានប្រៀបលើយើង។ ត្រូវតែការពារខ្លួនជានិច្ច ហើយប្រឆាំងជាមួយពួកវារហូតនៅឆ្នាំ១៩៧៧ រហូតធ្វើយ៉ាងម៉េចកម្ទេចវាកុំវាងើបក្បាលរួច"។

ERN ជាភាសាអង់គ្លេស 00478501, ERN ជាភាសាបារាំងគឺ 00499758, ERN ជាភាសាខ្មែរ 00062991 លោកលើកឡើងដូចៗតទៅនេះ ខ្ញុំដកស្រង់៖ "ត្រូវតែបំពាក់បំប៉នមហាជនដោយបង្ខំដើម្បីឱ្យចាប់ខ្មាំង ហើយនិងវិភាគដោយដាក់រកខ្មាំង ហើយនិងដាក់សម្ពាធលើខ្មាំង ចាប់ខ្មាំង កម្ទេចខ្មាំង ធ្វើយ៉ាងណាឱ្យខ្មាំងហ្នឹងក្លាយជាកណ្តុរដែលគេព័ទ្ធវាយកម្ទេចចោល"។ បាទ សូមបញ្ចប់ការដកស្រង់។ លោក ឌុដម៉ាន តើជាការត្រឹមត្រូវដែរឬទេថា លោកមិនបានពិគ្រោះឯកសារប្រភេទនេះទេ នៅពេលដែលលោកសរសេរអត្ថបទរបស់លោកនៅខែធ្នូ ឆ្នាំ១៩៧៨នោះ? ហើយៗតើលោកបានពិគ្រោះឯកសារបែបនេះទេ នៅឆ្នាំ៨០បាទ?

[០៩:៤១:២៨]

**ឆៈ** បាទ ត្រូវហើយខ្ញុំមិនដឹងថា មានឯកសារទាំងអស់នេះទេ កាលនុ៎ងនោះ។

**សៈ** ព័ត៌មានទាំងអស់នេះ ទំនងជាអាចឆ្លើយតបទៅនឹងសំណួរដែលលោកចោទនៅចុងអត្ថបទរបស់លោកបាន នៅពេលដែលលោកសួរថាៗ តើខ្មែរក្រហម – មេដឹកនាំខ្មែរក្រហមហ្នឹង ជំរុញឱ្យមានអំពើហិង្សាដែរឬអត់នោះ?

**ឆ៖** បាទ តាមមើលទៅដូចជាពិតហើយ ដែលគេជំរុញឲ្យមានការប្រព្រឹត្តអំពើហិង្សានេះ។

**ស៖** *(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

ឈប់! អ៊ូ!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអន្តរាគមន៍ កម្រអន្តរាគមន៍ណាស់ ចំពោះសំណួរដែលចោទទៅភាគីនេះ ព្រោះខ្ញុំគិតថា យើងឥឡូវសុទ្ធៗតែជាអ្នកអាជីព។ អ៊ីចឹងគឺថា វាមានពេលខ្លះ យើងអាចឲ្យគេចោទសំណួរបានតាមចិត្ត ក៏ប៉ុន្តែពេលខ្លះ ការប្រើឯកសាររបស់សហព្រះរាជអាជ្ញានេះ ប៉ុន្មាននាទីចុងក្រោយនោះ ដូចៗជាមិនសំដៅទៅចោទៗសំណួរទេ ស្មើនឹងការការធ្វើការសន្និដ្ឋានបញ្ចប់ការដេញដោលហើយ។ អ៊ីចឹង លោកសាក្សីនេះ គាត់ជា -- ឌុងម៉ាន ជាសាក្សីគាត់ចោទ ពេលខ្លះគាត់ឆ្លើយថា គាត់មិនចាំ គាត់មិនដឹង។ អ៊ីចឹងសំណួររបស់ -- អ៊ីចឹងបើតាមខ្ញុំមើលទៅ សំណួរដែលព្រះរាជអាជ្ញាសួរនេះ ជាសំណួរដែលមានចម្លើយហើយស្រាប់បាត់ទៅហើយ។ អ៊ីចឹងយើងមិនមែនជានៅក្នុងសវនាការនេះ ដើម្បីនិយាយតែពីឯកសារទេ។ អ៊ីចឹង សូមឲ្យ បើអ៊ីចឹងសូមឲ្យគាត់ចោទសំណួរហ្នឹង មុនចោទសំណួរឲ្យមានមូលដ្ឋានសិន កុំឲ្យយកឯកសារមកដាក់យ៉ាងដូច្នេះ។

[០៩:៤៣:១១]

**លោក ឌេល លីសាក់៖**

បាទ ខ្ញុំឆ្លើយតប លោកប្រធាន។ មេធាវីការពារក្តីបានដាក់ឯកសារដែលអត្ថបទដែលគាត់ចោទបានសរសេរនៅឆ្នាំ១៩៩០នេះ តាមពិតទៅនោះ។ អ៊ីចឹង ខ្ញុំមានសិទ្ធិផ្ទៀងផ្ទាត់ជាមួយនឹងសាក្សី ថាគាត់បានពិគ្រោះឯកសារហ្នឹងដែរឬអត់។ គាត់ ហើយសួរថាតើអ្វីដែលគាត់សរសេរហ្នឹង គឺថាមានផលប៉ះពាល់យ៉ាងណាខ្លះ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបម្តងទៀត។ ត្រង់នេះហើយនូវបញ្ហានោះ គឺថាយើងសួរសាក្សីឲ្យឆ្លើយស្មានៗ។ បញ្ហានោះគឺថាមិនត្រូវដឹងថា តើសាក្សីនោះបានធ្វើអីនៅខ្លះទេ យើងត្រូវដឹងថាតើគាត់បានឃើញអី គាត់បាននិយាយអី។ បើអ៊ីចឹង បើពេលដែលគាត់អត់ដឹងផង គាត់អត់បានឃើញផង គាត់មិនអាចផ្តល់សក្ខីកម្មទេ សួរទាក់ទងនឹងឯកសារដែលអាននុ៎ង មិនត្រូវទេ។ អ៊ីចឹងគាត់មិនមែនជាអ្នក

ជំនាញទេ អ៊ីចឹងគាត់ជាសាក្សីអង្គហេតុទេ។ អ៊ីចឹងត្រូវសួរគាត់ក្នុងលក្ខខណ្ឌជាសាក្សីអង្គហេតុ។ គាត់មិនដឹង មិនត្រូវសួរគាត់ទេ។

[០៩:៤៤:១៨]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៦:០៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ដើម្បីសម្រេចលើសេចក្តីជំទាស់នេះ ចំពោះការតាំងសំណួរ -- របៀបតាំងសំណួររបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដោយក្រុមមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។

បាទ សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យើងសង្កេតឃើញថា យើងទុកឱកាសឲ្យសួរសំណួរ លទ្ធភាពសួរច្រើនសម្រាប់សាក្សីនេះ ហើយយើងក៏បានធ្វើយ៉ាងដូច្នេះដែរសម្រាប់មេធាវីការពារក្តី អនុញ្ញាតឲ្យធ្វើដូចគ្នា។ យើងទទួលឲ្យចោទសំណួរជាច្រើន ពេលខ្លះដែលសំណួរឲ្យឆ្លើយស្មាន យើងអនុគ្រោះឲ្យធ្វើយ៉ាងដូច្នេះ ហើយខាងការពារក្តី ក៏យើងអនុញ្ញាតឲ្យធ្វើយ៉ាងដូច្នេះផងដែរ។ ក៏ប៉ុន្តែមើលទៅហាក់ដូចជា -- ការចងចាំរបស់សាក្សី មើលទៅដូចជាមានកម្រិតណាស់។ ដូច្នេះ គឺសូមឲ្យអញ្ជើញ ឬក៏បង្គាប់ឲ្យសាក្សី -- អ៊ំ! ឲ្យភាគីទាំងអស់នោះ ចោទសំណួរណាដែលសាក្សីអាចឆ្លើយបាន។ ពីព្រោះថា នៅពេលដែលយើងបង្ហាញឯកសារទៅសាក្សី ហើយឲ្យសួរបញ្ជាក់ អ្វីដែលគាត់មិនដឹង ហើយគាត់អត់ដឹងផង។ ហើយថាសួរថាបើសិនជាដឹងវិញនោះ តើធ្វើយ៉ាងម៉េចដែរ? អ៊ីចឹងខ្ញុំយល់ឃើញថា ហាក់ដូចជាជ្រុលពេកហើយ សូមកុំឲ្យសួរយ៉ាងដូច្នេះទៀត។

**លោក ឌេល លីសាក់៖**

តើខ្ញុំមានសិទ្ធិសួរទៅសាក្សីថា តើគាត់មានបានពិគ្រោះឯកសារណាមួយចំនួនទេ នៅពេលដែលគាត់សរសេរអត្ថបទរបស់គាត់នេះ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ធម្មតា លោកមានសិទ្ធិសួរជាទូទៅ ក៏ប៉ុន្តែមិនមែនពេលក្រោយអានឯកសារផ្នែកសម្រង់ហ្នឹង

ទាំងអស់ហ្នឹងឲ្យទៅសាក្សីនោះទេ។ ខ្ញុំគិតថាលោកអាចចោទសំណួរទៅគាត់ជាលក្ខណៈទូទៅបាន។

[០៩:៤៨:២៧]

**លោក ខេល លីសាក់៖**

បាទ ខ្ញុំនឹងព្យាយាមធ្វើតាម។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោក ឌុដម៉ាន ខ្ញុំនឹងសួរទៅគាត់អំពីភស្តុតាងដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿង។ មានតេឡេក្រាម ហើយនិងរបាយការណ៍រាប់រយរាប់ពាន់នោះ ដែលយើងបានទទួល។ អ្វីដែលខ្ញុំចង់ដឹងនោះ នៅពេលដែលលោកមកកម្ពុជាប្រជាធិបតេយ្យនោះ តើលោកបានពិគ្រោះតេឡេក្រាម ហើយនិងរបាយការណ៍ទាំងអស់នោះ នៅក្នុងប្រទេសកម្ពុជាហ្នឹងដែរឬទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

អានេះ ខ្ញុំមើលទៅឃើញដូចសំណួរនេះគួរឲ្យអស់សំណើច។ មិនដែលមានរដ្ឋាភិបាលណាផ្តល់ឲ្យអ្នកកាសែតពិគ្រោះតេឡេក្រាម ឬក៏របាយការណ៍ជាតិនោះទេ។ អ៊ីចឹង វាជារឿងច្បាស់ណាស់ ថាលោក ឌុដម៉ាន នោះ គាត់មិនបានពិគ្រោះឯកសារប្រភេទហ្នឹងទេ។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោក ឌុដម៉ាន តើលោកបានពិគ្រោះឯកសារបែបនេះដែរឬទេ ពេលលោកមកកម្ពុជាប្រជាធិបតេយ្យ? តើលោកធ្លាប់បានអានរបាយការណ៍ ឬក៏តេឡេក្រាមមុននឹងលោកសរសេរអត្ថបទលោកនៅឆ្នាំ១៩៨០ដែរឬទេ?

**លោក រីឆាដ ឌុដម៉ាន៖**

**ឆ៖** ខ្ញុំមិនចាំថា ខ្ញុំបានពិគ្រោះឯកសារប្រភេទនេះនោះទេ ដូចជាទូរលេខ ឬក៏របាយការណ៍នោះ។

[០៩:៥០:០០]

**ស៖** ខ្ញុំសួរជិតចប់ហើយលោក ឌុដម៉ាន។ តើលោកស្ថិតនៅក្នុងចំណោមអ្នកកាសែតនៅសហរដ្ឋអាមេរិក ដែលគេចាត់ទុកថា -- ដែលគេដាក់នៅក្នុងបញ្ជីខ្មាំងរបស់ប្រធានាធិបតី និចសុន?

**ឆ៖** បាទ ត្រូវហើយ។

**ស៖** តើបញ្ជីឈ្មោះខ្មាំងនេះ លោកអាចរៀបរាប់បន្តិចបានទេ ពាក់ព័ន្ធនឹងបញ្ជីនេះ?

**ឆ៖** ខ្ញុំគិតថា ចំណាងជើងបញ្ជីនេះច្បាស់ហើយ គឺពាក្យ គឺថារដ្ឋបាលនោះគេត្រូវដឹងថា អ្នកណាជាខ្មាំង ខ្មាំងជាអ្នកណានោះ។ អ៊ីចឹងច្បាស់ហើយ។

**សៈ** នៅពេលដែលគេដាក់លោកក្នុងបញ្ជីខ្មាំងហើយ តើលោកត្រូវបានគេៗ ចាប់ហើយបញ្ជូនទៅអប់រំដោយរដ្ឋាភិបាលអាមេរិកាំងដែរឬទេ?

**ឆ៖** អត់ទេ។

**សៈ** តើលោកនៅតែបន្តធ្វើការនៅក្នុងកាសែតសំខាន់ជាងគេរបស់អាមេរិក ឧទាហរណ៍ដូចជាប្រធានការិយាល័យនៅវ៉ាស៊ីនតោននោះ ដោយសារលោកមានឈ្មោះអាក្រក់ក្នុងបញ្ជីហើយ?

**ឆ៖** បាទ ខ្ញុំនៅតែបន្តធ្វើការដដែល ហើយខ្ញុំកាន់តែមានគោលជំហររឹងមាំទៀតផង។

**សៈ** បន្ទាប់ពីការទៅសង្កេតរបស់លោកនៅកម្ពុជាប្រជាធិបតេយ្យនេះ តើអ្នកជំទាស់ អ្នកប្រឆាំងនៅប្រទេសកម្ពុជា ដែលស្ថិតនៅក្នុងបញ្ជីអ្នកប្រឆាំងនោះ តើជោគវាសនាគេយ៉ាងម៉េចដែរ?

**ឆ៖** បាទ ខ្ញុំគិតថា ពួកគេត្រូវបានសម្លាប់ទាំងអស់។

[០៩:៥២:០៤]

**សៈ** បាទ ខ្ញុំសូមចូលទៅប្រធានបទថ្មីមួយទៀត គឺឯកសារ E333.1 គឺជារបាយការណ៍ចុះថ្ងៃទី១៨ ធ្នូ ឆ្នាំ១៩៧៨ សរសេរដោយកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ ស្តីអំពីទស្សនកិច្ចរបស់លោកនៅក្នុងប្រទេសកម្ពុជា, ឯកសារ ERN ជាភាសាអង់គ្លេស 01054091, ជាភាសាខ្មែរ 01047240, ERN ជាភាសាបារាំង 01054095។ អ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យបានសរសេររបាយការណ៍ទាំងអស់នេះ។ ខ្ញុំសូមដកស្រង់៖ "អ្នកកាសែតអាមេរិកាំងទាំងពីរនាក់ គឺបម្រើផលប្រយោជន៍រដ្ឋាភិបាលអាមេរិកាំង ហើយនិង សេ.អ៊ី.អា ហើយយើងបានកំណត់អត្តសញ្ញាណពួកគេច្បាស់ណាស់"។ តើលោកយល់យ៉ាងណាដែរអំពីការអះអាងរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យនេះ? លោកដែលគេត្រូវបានចាត់ទុកលោកជា ខ្មាំងរបស់សហរដ្ឋអាមេរិក និចសុន ទៅហើយ ហើយដល់ទៅមកស្រុកខ្មែរ ស្រាប់តែគេចាត់ទុកថាលោកជាបម្រើឲ្យផលប្រយោជន៍ សេ.អ៊ី.អា ទៀត?

**ឆ៖** បាទ នេះជាការកុហកទេ។

**លោក ខេល លីសាក់៖**

បាទ សូមអរគុណលោក ឌុដម៉ាន ដែលបានមានធ្វើការអត់ធ្មត់។ ខ្ញុំអានឯកសារជាច្រើនជូនលោកស្តាប់ ហើយខ្ញុំសូមអរគុណច្រើនដែលលោកបានប្រឹងប្រែងមកផ្តល់សក្ខីកម្មនៅតុលាការខ្មែរ

ក្រហមនេះ។ លោកប្រធាន សូមអរគុណ។ ខ្ញុំចប់ហើយលោកប្រធាន។

[០៩:៥៣:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោក ឌុងម៉ាន ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍។ ខ្ញុំជាមេធាវីតំណាងឲ្យក្រុមដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿងនេះ។ ខ្ញុំនឹងព្យាយាមគោរពតាមការលើកឡើងរបស់លោកស្រីចៅក្រមហ្វេនស៍ គឺខ្ញុំព្យាយាមធ្វើយ៉ាងម៉េចទទួលបានចម្លើយពីសាក្សី ដោយព្យាយាមឲ្យគាត់ឆ្លើយតបទៅនឹងសក្ខីកម្មមួយចំនួនដែលយើងបានស្តាប់រួចមកហើយតាំងពីពេលចាប់ផ្តើមសវនាការនេះ តាំងពីដំបូងមកនោះ។ លោក ឌុងម៉ាន ខ្ញុំចាប់ផ្តើមដកស្រង់ឯកសារមួយចំនួន។ ឯកសារមួយចំនួនត្រូវបានសហព្រះរាជអាជ្ញាបានដកស្រង់រួចមកហើយ ហើយខ្ញុំនឹងនិយាយអំពីបញ្ជីសំណើរបស់លោកដែលលោកបានស្នើទៅមន្ត្រីកម្ពុជា ប្រជាធិបតេយ្យដែលបានរៀបចំកិច្ចទស្សនកិច្ចរបស់លោកនៅខែធ្នូ ឆ្នាំ១៩៧៨ គឺឯកសារលេខ E3/1156។ នៅក្នុងឯកសារនេះ នៅក្នុងកថាខណ្ឌ២ មានការពន្យល់អំពីការស្នើសុំរបស់លោកនៅលេខ៦ សំណើមួយរបស់លោកនោះ ក្នុងក្របខ័ណ្ឌនៃទស្សនកិច្ចរបស់លោកនោះគឺចង់មើលចលនាកងចល័ត និងចាត់តាំងសហករណ៍ ហើយមើលសហករណ៍ពីរឬបី។ សំណួរទី១ របស់ខ្ញុំពាក់ព័ន្ធទៅនឹងសំណើជាក់លាក់របស់លោកនេះ។ តើលោកមានចាំទេថាលោកបានទទូចដើម្បីអាចទៅមើលសហករណ៍ក៏ដូចជាការចាត់តាំងរបស់សហករណ៍ និងជាពិសេសនោះគឺថាចង់មើលចលនារបស់កងចល័តនោះ?

**ឆ៖** ខ្ញុំអត់ចាំសំណើសុំរបស់ខ្ញុំនេះទេ។

**ស៖** សូមអរគុណលោក ឌុងម៉ាន។ ជាលក្ខណៈទូទៅ តើលោកអាចពន្យល់ជូនអង្គជំនុំជម្រះបានទេអំពីអ្វីដែលលោកចាំ អំពីទស្សនកិច្ចសហករណ៍ដែលលោកបានធ្វើនៅក្នុងពេលដែលលោកស្នាក់

នៅកម្ពុជាប្រជាធិបតេយ្យនៅខែធ្នូ ឆ្នាំ១៩៧៨នោះ? ខ្ញុំសួរសំណួរដំបូងគឺថាតើលោកចាំអំពីចំនួនសហករណ៍ដែលលោកបានទៅមើលទេ?

**ឆ៖** ខ្ញុំអត់ចាំទេ។

**ស៖** ជាទូទៅ តើលោកចាំថាលោកបានទៅមើលសហករណ៍ទេអ៊ីចឹង?

**ឆ៖** ខ្ញុំនឹកអត់ឃើញទេលោកស្រី។

**ស៖** តើលោកមាននឹកឃើញទេថា លោកនិងលោកស្រី បេកឃ័រ និងលោក ខាដវែល ថាលោកបានទៅសហករណ៍លាយបូរនៅខេត្តតាកែវ។ លោកមានបាននឹកឃើញថាបានទៅមើលសហករណ៍លាយបូរហ្នឹងទេ?

**ឆ៖** ខ្ញុំនឹកអំពីដំណើរទស្សនកិច្ចនេះអត់ឃើញទេ។

[០៩:៥៨:០៥]

**ស៖** សូមអរគុណលោកសាក្សី។ តើលោកមាននឹកឃើញអ្វីខ្លះទេអំពីអ្នកដែលកំពុងធ្វើការនៅពេលដែលលោកទស្សនកិច្ចនៅឆ្នាំ១៩៧៨នោះ? បើសិនជាបានឃើញ តើលោកអាចពន្យល់បានទេថាឃើញយ៉ាងម៉េចខ្លះ? ថាឃើញមនុស្សធ្វើការនៅតាមការដ្ឋានហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំបាន ខ្ញុំចាំតែអ្វីដែលខ្ញុំបានសរសេរតែប៉ុណ្ណោះ។

**ស៖** សូមអរគុណលោកសាក្សី។ តើលោកអាចពន្យល់បានទេថា លោកមានចាំអំពីការពិភាក្សាជាមួយនឹងអ្នកដែលលោកបានជួបនៅសម័យនោះ មានបានពិភាក្សាអំពីលក្ខខណ្ឌការងារនៅសហករណ៍ទេ? ហើយបើសិនបើលោកបានពិភាក្សាជាមួយនឹងមន្ត្រីខ្មែរក្រហមនោះ តើលោកចាំទេថាលោកបានពិភាក្សាគ្នាអ្វីខ្លះ?

**ឆ៖** ខ្ញុំអត់ចាំពីចំណុចនេះទេ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកសាក្សី។ លោកប្រធានខ្ញុំគិតថា ឥឡូវនេះយើងដូចជាដល់ម៉ោងហើយ។ អ៊ីចឹងខ្ញុំសុំឆ្លៀតឱកាសនៅពេលដែលសម្រាកនេះ ខ្ញុំអាចរៀបចំសំណួរឲ្យបានល្អដើម្បីអាចសួរសាក្សីឲ្យបានច្បាស់លាស់ ហើយនិងមានសម្រង់អត្ថបទជាក់លាក់។ អ៊ីចឹង ការធ្វើបែបនេះគឺធ្វើឲ្យគាត់នឹកឃើញចងចាំបានល្អ។ អ៊ីចឹងឥឡូវនេះ យើងដល់ម៉ោងដប់ហើយ អ៊ីចឹងខ្ញុំសុំបញ្ចប់ត្រឹមនេះ ហើយសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបន្តទៅថ្ងៃស្អែកទៀតប្រហែលជា៣០នាទីទៀត លោកប្រធាន។

[១០:០០:១៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះសូមអរគុណលោក រីឆាដ ឌុដម៉ាន ដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោកនៅថ្ងៃនេះដល់ពេលសម្រាកហើយ ដូច្នេះលោកអាចសម្រាកបានហើយ។ អង្គជំនុំជម្រះសូមជម្រាបលោក រីឆាដ ឌុដម៉ាន ថាការស្ដាប់សក្ខីកម្មរបស់លោកនៅមិនយប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកផ្ដល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍នៅថ្ងៃស្អែក ថ្ងៃពុធ ទី០១ ខែមេសា ឆ្នាំ២០១៥ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ រហូតដល់ម៉ោងដប់ព្រឹក -- ពីម៉ោងប្រាំបីចាប់ផ្ដើមពីម៉ោងប្រាំបីព្រឹករហូតដល់ម៉ោងដប់ព្រឹក ម៉ោងនៅកម្ពុជា គឺនៅពេលម៉ោងដដែល។ ហើយអង្គជំនុំជម្រះក៏សូមអរគុណចំពោះលោក ដេវីដ ចេសិន បារ៉ែត និងលោក ថូដ ឡូវែល អង្គជំនុំជម្រះអញ្ជើញលោកទាំងពីរមកបន្តចូលរួម អង្គុយក្បែរសាក្សីនៅក្នុងអំឡុងពេល រីឆាដ ឌុដម៉ាន ផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបីព្រឹកម៉ោងនៅកម្ពុជា គឺនៅម៉ោងដដែល។ ហើយលោក រីឆាដ ឌុដម៉ាន, លោក ចេសិន បារ៉ែត និងលោក ថូដ ឡូវែល អាចសម្រាកបានហើយ។

**លោក រីឆាដ ឌុដម៉ាន៖**

សូមអរគុណលោកប្រធាន។

[១០:០១:៥០]

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះបង្គាប់ឲ្យខាងផ្នែកសោតទស្សន៍សម្របសម្រួលប្រព័ន្ធសោតទស្សន៍ត្រឡប់មកស្ថានភាពធម្មតាឡើងវិញ ហើយជាបន្តទៅនេះអង្គជំនុំជម្រះនឹងធ្វើកិច្ចនីតិវិធីចំនួនពីរ មួយ គឺចេញសេចក្ដីសម្រេចផ្ទាល់មាត់លើសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ហើយពីរស្ដាប់នូវសំណើសុំរបស់មេធាវីការពារក្ដី នួន ជា ដែលពាក់ព័ន្ធជាមួយនឹងការសេចក្ដីថ្លែងទុក្ខសោកវេទនារបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលពាក់ព័ន្ធទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់ខ្លួននៅក្នុងសំណុំរឿង ០០២/០១ ហើយនិងស្ដាប់សារណារបស់ភាគីពាក់ព័ន្ធទៅនឹងសំណើនេះ។

បាទ ជាដំបូងនេះអង្គជំនុំជម្រះផ្សព្វផ្សាយនូវសេចក្ដីសម្រេចផ្ទាល់មាត់លើសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ E342។

នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ អង្គជំនុំជម្រះបានទទួលសំណើមួយពីសហព្រះរាជអាជ្ញាអន្តរជាតិ សុំបញ្ចូលសៀវភៅមួយក្បាលដែលមានចំណងជើងថា "បងប្អូនរួមអាវុធ៖ ជំនួយចិនឲ្យទៅខ្មែរក្រហម ឆ្នាំ១៩៧៥-១៩៧៩" និពន្ធឡើងដោយ អេនឌ្រូ មេតា *(Andrew Mertha),* ឯកសារ E342។ អង្គជំនុំជម្រះចាំបាច់ត្រូវវាយតម្លៃថាតើលក្ខខណ្ឌនៅក្នុងវិធាន៨៧(៣)នៃវិធានផ្ទៃក្នុងត្រូវបានបំពេញដែរឬយ៉ាងណា? អង្គជំនុំជម្រះកត់សម្គាល់ថា សៀវភៅនេះមានតែជាភាសាអង់គ្លេសប៉ុណ្ណោះដែលមានចំនួនដល់ទៅ១៧៥ ទំព័រ ហើយសំណើនេះត្រូវបានដាក់នៅដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធី។ ដើម្បីឲ្យអង្គជំនុំជម្រះសម្រេចទាន់ពេលវេលា អង្គជំនុំជម្រះស្នើឲ្យសហព្រះរាជអាជ្ញាអន្តរជាតិដាក់សំណើសុំថ្មីមួយ ដោយកំណត់អត្តសញ្ញាណត្រង់ផ្នែកនានានៃសៀវភៅដែលពាក់ព័ន្ធនៅក្នុងរយៈពេលពីរសប្តាហ៍។ ប្រសិនបើសហព្រះរាជអាជ្ញាអន្តរជាតិមិនបានដាក់សំណើថ្មីនេះក្នុងពេលកំណត់នេះទេ នោះសំណើសុំបញ្ចូលសៀវភៅនេះធ្វើជាភស្តុតាងនឹងត្រូវចាត់ទុកជាអសារបង់។

បាទ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីបង្ហាញនូវសំណើសុំរបស់ខ្លួន ហើយនិងសារណាពាក់ព័ន្ធគាំទ្រនឹងសំណើរបស់ខ្លួន។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមអរគុណដែលអង្គជំនុំជម្រះអនុញ្ញាតឲ្យខ្ញុំធ្វើសំណើផ្ទាល់មាត់ទាក់ទងទៅនឹងសំណើសុំដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់ដើម-រដ្ឋប្បវេណី នៅថ្ងៃព្រហស្បតិ៍ និងថ្ងៃសុក្រ។ កាលពីម្សិលមិញ យើងខ្ញុំបានផ្ញើតាមរយៈអ៊ីម៉ែល នូវសម្រង់ចេញពីសារណាបណ្តឹងសាទុក្ខ នៅក្នុង១ គឺសារណាបណ្តឹងសាទុក្ខរបស់យើងខ្ញុំ។ ហើយនៅក្នុងសារណាបណ្តឹងសាទុក្ខនេះ យើងបានជំទាស់ថា នៅក្នុងសាលក្រមលើសំណុំរឿង០០២/០១--

[១០:០៦:១០]

*(គ្មានការបកប្រែ)*

[១០:០៦:២៣]

**ប្រធានអង្គជំនុំ៖**

លោក១ វ៉ិចទ័រ កូប៉េ ដូចមានបញ្ហាបកប្រែភាសា។

មន្ត្រីរដ្ឋបាលតុលាការពិនិត្យបញ្ហាបកប្រែភាសា។

បាទ ចាប់ម្តងទៀតលោក វ៉ិចទ័រ កូប៉េ អំមិញអត់មានការបកប្រែភាសាមួយ១ផ្នែកធំ។

**លោក វ៉ិចទ័រ កូប៉េះ**

បាទ ខ្ញុំសូមចាប់ផ្តើមឡើងវិញ លោកប្រធាន។ កាលពីម្សិលមិញ យើងខ្ញុំបានស្នើសុំទទួលបាននូវការអនុញ្ញាត ដើម្បីផ្តល់នូវសំណើបន្ថែមទៅលើសំណើសុំថ្មី ដែលទាក់ទងទៅនឹងសំណើរបស់មេធាវីនាំមុខតំណាងរដ្ឋប្បវេណី ពាក់ព័ន្ធទៅនឹងសក្ខីកម្មដែលត្រូវបានកំណត់ សម្រាប់ធ្វើនៅថ្ងៃព្រហស្បតិ៍ និងថ្ងៃសុក្រនេះ។ ហើយកាលពីម្សិលមិញ យើងខ្ញុំបានផ្ញើជូនអង្គជំនុំជម្រះនូវពីរបីកថាខណ្ឌ មិនមែនចេញពីសារណាបញ្ចប់ការសួរដេញដោលទេ ប៉ុន្តែចេញពីសារណានៃបណ្តឹងសាទុក្ខ គឺជាសម្រង់ចេញពីបណ្តឹងសាទុក្ខ ដែលយើងរិះគន់ទៅលើសាលក្រម ដែលថាសក្ខីកម្មហ្នឹង វាមានចំនួនលើសរហូតទៅដល់២៥០ដង ទៅនឹងសក្ខីកម្មដែលយើងបានផ្តល់មកកន្លងមក ដើម្បីយកប្រើប្រាស់ ដែលពាក់ព័ន្ធទៅនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ។ យើងខ្ញុំយល់ឃើញថា ទោះបីជាអង្គជំនុំជម្រះបានកំណត់យ៉ាងច្បាស់រួចមកហើយថា តើច្បាប់វាយ៉ាងម៉េចពាក់ព័ន្ធទៅនឹងបញ្ហាហ្នឹង អង្គច្បាប់និយាយថាម៉េច ប៉ុន្តែយើងខ្ញុំមិនច្បាស់ទេ ថាចំណុចនេះវានឹងមិនកើតមានឡើងម្តងទៀតនោះទេ នៅពេលដែលអង្គជំនុំជម្រះនឹងសរសេរសាលក្រមនៅក្នុងរឿងក្តីកំពុងតែដេញដោលនេះ។

[១០:០៨:២៨]

ពាក់ព័ន្ធទៅនឹងការជំទាស់តវ៉ារបស់យើងខ្ញុំដែលបានលើកឡើងនោះ នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់យើងខ្ញុំ គឺថាអ៊ីចឹងហើយ បានខ្ញុំថាសំណើផ្ទាល់មាត់នេះ គឺថាវាមានការពាក់ព័ន្ធ។ ការដែលជំទាស់តវ៉ានេះ ខ្ញុំជឿជាក់ថា គឺខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនោះ គឺថាការកំណត់បែបនេះ វាមិនជាមានមធ្យោបាយមួយអាចដោះស្រាយស្ថានភាពនេះឲ្យបានទៀតទេ ប៉ុន្តែសម្រាប់ថ្ងៃព្រហស្បតិ៍ ថ្ងៃសុក្រនេះ ខ្ញុំដឹងថា គឺយើងបានកំណត់បានផ្តល់ពេលវេលា គឺ១ម៉ោង៥នាទី សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុមៗ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ហើយដែលយើងត្រូវសួរសក្ខីកម្មយកមកប្រើប្រាស់ជាភស្តុតាង។

ហើយយើងខ្ញុំក៏សូមស្នើអង្គជំនុំជម្រះថា មេត្តាចែកពេលវេលានេះឲ្យបានប្រើ -- ឲ្យបានស្មើគ្នាពាក់ព័ន្ធទៅនឹងការតាំងសំណួរពីសំណាក់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលៗគេដែលប្រើប្រាស់ពេលវេលាសួរទៅនឹងព្រឹត្តិការណ៍ ហើយនិងព្រឹត្តិការណ៍ដែលត្រូវយកមកវិនិច្ឆ័យនៅក្នុងសវនាការនេះ។ ខ្ញុំលើកជាឧទាហរណ៍ថា ប្រសិនណាជាដើមបណ្តឹងរដ្ឋប្បវេណី ឧទាហរណ៍ថា ទទួលរងព្យសនកម្មក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ រៀបរាប់ -- ដើមបណ្តឹងរដ្ឋប្បវេណីរៀបរាប់ថា ខ្លួនទទួលរងការ

ឈឺចាប់ណាមួយនោះ គឺថាយើង គឺថាមិនសូវមានសិទ្ធិតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីនោះ។ ហើយប៉ុន្តែបើសិនណាជាដើមបណ្តឹងរដ្ឋប្បវេណីផ្តល់សក្ខីកម្មថា អត់មានស្បៀងបគ្រប់គ្រាន់ទេ កុមារៗស្លាប់ដោយសារតែការកង្វះអាហារូបត្ថម្ភ សាច់ញាតិរបស់គេបញ្ជូនទៅមន្ទីរអប់រំកែប្រែជាដើម។ល។ ដូច្នេះគឺថា ភស្តុតាងបែបនេះគឺវាពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលកំពុងតែធ្វើការវិនិច្ឆ័យទោសនេះហើយ។ ប៉ុន្តែយើងខ្ញុំក៏ត្រូវតែមានឱកាសដើម្បីសួរផ្ទុយទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះផងដែរ។ ហើយជាការពិតហើយគឺថា យើងខ្ញុំនឹងមិនស្នើសុំទេ បើសិនណាជានៅបញ្ចប់នៃកិច្ចដំណើរការនីតិវិធីនេះ អង្គជំនុំជម្រះមិនយកសម្តី ឬក៏ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីមកធ្វើជាភស្តុតាង យើងនឹងមិនជំទាស់នោះទេ។

ហេតុដូច្នេះឯង សរុបសេចក្តីមកវិញសម្រាប់ការជំទាស់របស់ខ្ញុំ សម្រាប់ថ្ងៃព្រហស្បតិ៍ និងថ្ងៃសុក្រនេះ ដែលយើងខ្ញុំជឿជាក់ថាយ៉ាងហោចណាស់ យើងខ្ញុំជឿជាក់ថា យើងខ្ញុំត្រូវមានពេលវេលាពាក់កណ្តាលនៃពេលវេលាដែលបានកំណត់មកឲ្យ លើកលែងតែដើមបណ្តឹងរដ្ឋប្បវេណីនិយាយអំពីតែការឈឺចាប់ផ្លូវចិត្ត និងផ្លូវកាយតែប៉ុណ្ណោះ ហើយដែលត្រូវកំណត់ដោយវិធានផ្ទៃក្នុងផងដែរ។ ប៉ុន្តែយើងមិនអាចប្រមើលជាមុនថា តើដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗនឹងនិយាយអំពីអ្វី ឬក៏ថាដើមបណ្តឹងរដ្ឋប្ប-វេណីនឹងត្រូវគេតាំងសំណួរសួរទៅដោយរបៀបណានោះទេ។ ហើយខ្ញុំស្នើសុំពីដំបូងថា យើងខ្ញុំត្រូវតែទទួលបាននូវពេលវេលាស្មើគ្នាទៅនឹងពេលវេលាដែលបានកំណត់ទៅឲ្យខាង មេធាវីដើមបណ្តឹងរដ្ឋប្ប-វេណី។ សូមអរគុណ។

[១០:១២:០៨]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមថ្លែងការព្រួយបារម្ភដូចមេធាវី នួន ជា ហ្នឹងដែរ។ នៅក្នុងក្របខ័ណ្ឌសំណុំរឿង០០២/១ ហ្នឹងគឺមានការបែងចែករវាងសវនាការដែលភាគី -- ដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវចូលនិយាយអំពីអង្គហេតុ ហើយនិងនិយាយអំពីបទពិសោធន៍ផ្ទាល់ខ្លួន ហើយនិងបែងចែកចេញពីផ្នែកមួយទៀតដែលគេហៅថា “ផ្នែកថ្លែងទុក្ខ” ដែលគាត់និយាយអំពីទស្សនៈរបស់គាត់ ការទទួលអារម្មណ៍របស់គាត់ដើម្បីឲ្យតុលាការអាចវាយតម្លៃលើកម្រិតឈឺចាប់របស់គាត់។

បញ្ហាដែលសហភាតារបស់ខ្ញុំបានលើកឡើងនេះ គឺយើងគឺថា តើឋានៈនៃការផ្ដល់សក្ខីកម្មនេះយ៉ាងម៉េចដែរ? តើតុលាការនឹងគិតថា ជា -- ស្ថិតនៅក្នុងក្របខ័ណ្ឌនៃការ -- បទពិសោធន៍ផ្ទាល់ខ្លួនដើម្បីមកផ្ដល់សក្ខីកម្មនៅទីនេះ ឬក៏ថាសក្ខីកម្មរបស់គាត់ហ្នឹងមានផលប៉ះពាល់ធ្ងន់ ដែលថាអាចចាត់ទុកជាឯកសារភស្តុតាង។ អ៊ីចឹងគោលជំហររបស់យើងហ្នឹង វាខុសគ្នាបើសិនថាគ្រាន់តែថា ពួកគាត់មកគ្រាន់តែនិយាយអំពីការឈឺចាប់ផ្ទាល់ខ្លួននោះទេ ឬក៏គាត់ចូលនិយាយទៅលើអង្គហេតុតែម្ដង ការនិយាយលើអង្គហេតុនេះ វាមានផលប៉ះពាល់ទៅលើការ -- មិននេះទេបើសិននិយាយអ៊ីចឹង យើងត្រូវតែការពារយើងត្រូវចោទសំណួរទៅលើគាត់ដែរ។ អ៊ីចឹងបើក្នុងករណីយើង ត្រូវការពេលវេលាច្រើន។ ដូចអង្គជំនុំជម្រះបានជម្រាបជូនស្រាប់ហើយនៅក្នុងសេចក្ដីសម្រេចពីមុនរបស់ខ្លួន គឺសេចក្ដីសម្រេចថា E236/5 ថ្ងៃទី០៧ កុម្ភៈ ឆ្នាំ២០១៥ -- ២០១៣។ អ៊ីចឹងថា តើទៅប្រើ -- បើសិនជាប្រើការថ្លែងទុក្ខហ្នឹង ជាភស្តុតាងដាក់បន្ទុក អ៊ីចឹងខ្ញុំគ្រាន់តែសុំបំភ្លឺបន្តិចទៀតទៅថា បើតាមពិតទៅ គឺថាតើបើសិនជាមានករណីថាយកទៅប្រើដាក់បន្ទុកអីយ៉ាងនេះ គឺថាយើងត្រូវតែសួរ មានសិទ្ធិសួរសំណួរទៅគាត់ ព្រោះថាវាចូលដល់ពីការនិយាយលើអង្គហេតុ។ គ្រាន់តែសូមបញ្ជាក់ប៉ុណ្ណឹងទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ។

[១០:១៥:៣០]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីទាំងអស់គ្នា។ ខ្ញុំមានការកត់សម្គាល់ខ្លីមួយទេ ទាក់ទងទៅនឹងនឹងមេធាវីដើមបណ្ដឹរដ្ឋប្បវេណី -- មេធាវី នួន ជា។ គាត់ថា មានសំណើ -- នៅថ្ងៃទី៣០ ខែ៣ គឺនិយាយទាក់ទងទៅនឹងការឈឺចាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិង -- បាទ ខ្ញុំសូមកត់សម្គាល់ថា ការនិយាយនៅទីនេះ និងអ្វីដែលគាត់បានផ្ញើទៅភាគីនោះ ខុសគ្នាអំណះអំណាងនោះ ដែលក្រុម នួន ជា ផ្ដល់ឲ្យនោះខុសគ្នា។ អំណះអំណាងនោះមានលក្ខណៈដាច់ខាតជាងនៅថ្ងៃនេះ។

អ៊ីចឹង ខ្ញុំឃើញថាសំណើនោះ វាដូចយឺតយ៉ាវបន្តិចហើយ។ មេធាវី នួន ជា បានដាក់ឯកសារ គឺដាក់បណ្ដឹងឧទ្ធរណ៍របស់ខ្លួន នៅចុងខែ១២ ឆ្នាំ២០១២ -- ២០១៤ បាទ ហើយអំណះអំណាងនេះ មករកឃើញ ទើបតែមាននៅឆ្នាំ២០១៥ គឺថ្ងៃ៣០ ខែ៣ ២០១៥ ដើម្បីមកបង្ហាញ ហើយមកសុំកែប្រែមុន

ពេលដើមបណ្ដឹងរដ្ឋប្បវេណីមកផ្ដល់សក្ខីកម្មតែប៉ុណ្ណោះ។ អ៊ីចឹង ខ្ញុំសូមកត់សម្គាល់ថា មេធាវី ការពារក្ដីលោក នួន ជា បានសុំឱ្យ មិនមែននិយាយនៅថ្ងៃនេះទេ គឺថាសុំឱ្យនិយាយដល់ថ្ងៃស្អែកទៀតផង ពីរឿងសំណើនេះ មុនពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីមកផ្ដល់សក្ខីកម្ម នៅពេលដែលពួកគាត់មកដល់ភ្នំពេញហើយសិន។ អនុស្សរណៈរបស់អង្គជំនុំជម្រះដែលពាក់ព័ន្ធនឹងចំណុចនេះ គឺឯកសារ E3 ចុះថ្ងៃ -- ចុះឆ្នាំ២០១៤--

**អ្នកបកប្រែ៖**

លោកប្រធាន ខ្ញុំចាប់លេខឯកសារអត់បាន លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារងអាចរៀបរាប់លេខឯកសារឡើងវិញ ហើយយឺតៗ ដើម្បីឱ្យអ្នកបកប្រែបកប្រែបាន ព្រោះអម្បាញ់មិញអ្នកបកប្រែបកប្រែមិនទាន់ទេ។

[១០:១៧:៤២]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ លោកប្រធាន គឺលេខ -- ខ្ញុំអត់បានលេខ ERN ទេ ប៉ុន្តែឯកសារនោះ គឺថា E315/1 ដែលចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ដែលទាក់ទងទៅនឹងសវនាការប្រភេទនេះ។ ទាក់ទងទៅនឹងការថ្លែងទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណី គឺថាពីកថាខណ្ឌ៧ដល់៩ នៃអនុស្សរណៈរបស់អង្គជំនុំជម្រះដែលចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤នេះ។ មេធាវីការពារក្ដីមានរយៈពេល៣ខែ ចាប់ពីពេលហ្នឹងមកនោះ ដើម្បីមកនិយាយអំពីខ្លឹមសារនៃសវនាការបែបនេះនោះ ហើយមិនគួរណាចាំដល់ពេលនាទីចុងក្រោយនេះហើយបានមកលើកសំណើនេះទេ។ អំណះអំណាងដែលបានលើកឡើងទៅឱ្យតុលាការកំពូល មេធាវី នួន ជា បាននិយាយអំពីការអនុវត្តនៅក្នុងប្រទេសប្រើច្បាប់ខំមិនឡ ឧទាហរណ៍ដូចជា អូស្ត្រាលី កាណាដា នូវែលសេឡង់ និងសហរដ្ឋអាមេរិកអីជាដើម ឬក៏អ៊ីស្រាអែលអីនេះ ប៉ុន្តែក្នុងប្រទេសទាំងអស់នេះ មិនមានដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។ អ៊ីចឹងតួនាទីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនេះត្រូវកំណត់ -- កម្រិតមកត្រឹមតែជាតួនាទីរបស់សាក្សី ឬក៏តួនាទីដែលទាក់ទងតែពាក់ព័ន្ធតែនឹងសវនាការដែលកម្រិតមកត្រឹមការកំណត់ទោសតែប៉ុណ្ណោះ។ ក៏ប៉ុន្តែមិនអាចកំណត់ពីពិរុទ្ធភាពជនជាប់ចោទនោះទេ។ នៅចំពោះមុខតុលាការយើងនេះ មានដើមបណ្ដឹងរដ្ឋប្បវេណីដែលតួនាទីរបស់គាត់មួយ គឺចូលរួមក្នុងការជំនុំជម្រះ ហើយនិងការចូលរួមការចោទប្រកាន់របស់សហព្រះរាជអាជ្ញា។ យុត្តិសាស្ត្រខាងខំមិនឡ ហើយនិង

ច្បាប់អន្តរជាតិនោះមិនពាក់ព័ន្ធទេ ហើយមិនអាចអនុវត្តបានទេនៅទីនេះ។

[១០:១៩:៣៧]

អង្គជំនុំជម្រះត្រូវរំឭកអំពីលទ្ធភាពអាចប្រើ ហើយភស្តុតាងដែលត្រូវបានបង្ហាញជូនដល់ខ្លួន។ ព្រោះថាភស្តុតាងទាំងអស់នេះត្រូវបានប្រមូលដោយស្របច្បាប់ ហើយនិងគួរឲ្យទុកចិត្តបាន ហើយភាគីអាចដេញដោលតទល់គ្នាបាន លើឯកសារទាំងអស់នេះ។ អ៊ីចឹង មានស្ថានភាពពីរចំពោះមុខតុលាការយើងនេះ គឺថាស្ថានភាពពីរនេះ គឺស្រដៀងគ្នា។ ទី១ គឺដើមបណ្តឹងរដ្ឋប្បវេណីត្រូវស្តាប់ទៅលើអង្គហេតុអំពីភស្តុតាង។ អ៊ីចឹងភាគីទាំងអស់នេះអាចសួរទៅដើមបណ្តឹងរដ្ឋប្បវេណីបានទាក់ទង អង្គហេតុនេះ។ ហើយនៅក្រោយទៀត ដល់ពេល -- ផ្នែកមួយទៀត គឺថាឲ្យគាត់ថ្លែងទុក្ខ ដោយយើងគោរព – ដោយថាគោរពច្បាប់តទល់គ្នា។ អង្គជំនុំជម្រះគឺថានៅផ្នែកពីរ -- ទី២ ដែលនិយាយពីការថ្លែងទុក្ខនោះ បើសិនជាមានព័ត៌មានថ្មីដែលដាក់បន្ទុកលើជនជាប់ចោទនោះ ភាគីអាចចោទសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីបាន។ អង្គជំនុំជម្រះបានសម្រេចយ៉ាងដូច្នេះ។ អ៊ីចឹងស្ថានភាពទី២ ដែលមានដែរនោះ ដែលយើងនឹងស្តាប់នៅថ្ងៃព្រហស្បតិ៍ ថ្ងៃសុក្រនេះ គឺថាដើមបណ្តឹងរដ្ឋប្បវេណីនឹងនិយាយ តែអំពីទុក្ខសោក ហើយនិងការឧក្រិដ្ឋកម្មដែលខ្លួនទទួលរងនោះទេ។ អ៊ីចឹងការពិភាក្សានៅមុខអង្គជំនុំ ជម្រះយើងនៅទីនេះ កាលនោះយើងបាន -- កាលនោះខ្ញុំ ហើយនិងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ ហើយថាយើងមិនអាចបែងចែកឲ្យបានដាច់ស្រឡះរវាងការទុក្ខសោកវេទនា ហើយនិងឧក្រិដ្ឋកម្មដែលចោទប្រកាន់នោះទេ។ ដើម្បីឲ្យយល់ច្បាស់ថា តើគាត់វេទនាយ៉ាងម៉េចខ្លះ ត្រូវតែដឹងថា វេទនាមកពីណា? អ៊ីចឹងវេទនាទុក្ខវេទនានោះមកពីអង្គហេតុ។ អ៊ីចឹងៗនៅពេលដែលមេធាវីការពារក្តីអាចចោទប្រកាន់ -- អាចចោទសំណួរបានទាក់ទងនឹងអង្គហេតុទាំងនេះ ទៅតាមរយៈឯកសារភស្តុតាង។

[១០:២១:៥៥]

នៅក្នុងសាលក្រម បើអ៊ីចឹងត្រូវតែសង្កតធ្ងន់ទៅលើថា នៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង00២/0១ យើងនេះ កន្លងមកនេះ ភាគីទាំងអស់មានឱកាសសួរសំណួរដែលខ្លួនចង់ទៅដើមបណ្តឹងរដ្ឋប្បវេណី ក្នុងរយៈពេល៤ថ្ងៃ ដែលសម្រាប់និយាយអំពីទុក្ខសោក ហើយនិងអំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្ម។ បើតាមបើខ្ញុំមិនច្រឡំទេ គឺនៅថ្ងៃទី២៩, ៣០ ខែឧសភា ឆ្នាំ២០១៣។ សវនាការនេះបានប្រព្រឹត្តទៅនៅប៉ុន្មានថ្ងៃហ្នឹង ហើយពេលវេលាកាលនោះមានកម្រិតណាស់ ក៏ប៉ុន្តែមានសំណួរចោទសួរច្រើន គឺសួរសំណួរដោយព្រះរាជអាជ្ញា ហើយនិងមេធាវីការពារក្តី ចោទសំណួរទៅនឹងអង្គហេតុ ហើយមិនមែនទៅលើទុក្ខ

សោកវេទនាទេ។ ដូច្នេះ មេធាវីការពារក្ដីមិនអាចនិយាយថា ខ្លួន -- ថាមិនអាចនិយាយថា ផ្នែកដែលនិយាយអំពីអង្គ -- និយាយអំពីការឈឺចាប់នេះ អាចយកទៅប្រើនៅក្នុងការធ្វើសាលក្រមនោះទេ។ នៅក្នុងសវនាការថ្ងៃទី២៧ ឧសភា ឆ្នាំ២០១៣ មេធាវី សុន អរុណ កាលនោះនៅម៉ោង ១១:៤២ និងម៉ោង ១១:៥៨ មេធាវី សុន អរុណ ចោទសំណួរទៅ អួន ផល្លី គាត់សួរ កាលនោះគាត់មិនសួរទៅលើការទុក្ខសោកវេទនាទេ គាត់សួរពីការជម្លៀសចេញពីទីក្រុងភ្នំពេញ ហើយសួរឲ្យដឹងថា អង្គាល់នោះថាតើមានការដាក់កំហិត ឬក៏ការប្រើប្រាស់អំពើហិង្សាដែរឬទេ កាលនោះ? ហើយមេធាវី កូប៉េ នោះក៏ចោទសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី យស ផល នៅថ្ងៃទី២៧ ឧសភា ឆ្នាំ២០១៣ អស់រយៈពេល២០នាទី គឺពីម៉ោង១៥:៤០ ហើយគាត់សួរដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងទៅនឹងជោគវាសនាអតីតទាហានយោធា -- ទាហាន លន់ នល់ នៅពេលជម្លៀសនោះ។ អ៊ីចឹងនេះមិនមែនជារឿងសួរពីរឿងទុក្ខវេទនាទេ សួររឿងអង្គហេតុហើយ។ មេធាវី អាកទួរ វែកគែន នោះក៏សួរប្រភេទអ៊ីចឹងដែរ។ គាត់សួរកាលនោះអស់រយៈពេល១០នាទី។ អ៊ីចឹងខ្ញុំអាចផ្ដល់ឧទាហរណ៍ច្រើនណាស់ទាក់ទងនឹងសវនាការទាំងបួនថ្ងៃនោះ ក៏ប៉ុន្តែអ៊ីចឹងគ្រាន់តែចង់ជម្រាបថា មេធាវីការពារក្ដីគាត់មានលទ្ធភាពសួរបាន ទោះបីជាពេលវេលាហ្នឹងមានកម្រិតក៏ដោយ។ ដូច្នេះ បញ្ហាឥឡូវនេះ គឺថា នួន ជា -- ឥឡូវ នួន ជា គាត់ចង់ចំណេញរហូតតែម្ដងបើគិតទៅ។ អ៊ីចឹងចង់ដាក់ ចង់ធ្វើឲ្យ -- ធ្វើតេស្ដមេ -- ដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងវាយប្រហារលើសក្ខីកម្មរបស់គាត់ ហើយនិងចង់ប្រាប់ទៅតុលាការកំពូលថា មិនអាចទទួលយកបានទេ ដែលអង្គជំនុំជម្រះសាលាដំបូងនេះប្រើសក្ខីកម្មពេលសម្រាប់ថ្លែងទុក្ខនេះ យកទៅធ្វើសាលក្រម។ អ៊ីចឹង នេះនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់គាត់ ក៏ប៉ុន្តែឥឡូវនេះ គាត់មកប្រាប់នៅទីនេះថា បើសិនជាប្រើភស្តុតាងទាំងអស់នេះ ដើម្បីដាក់បន្ទុកនោះ នឹងមានបញ្ហា បាទ។

[១០:២៥:២៣]

ខ្ញុំសុំឆ្លើយតបថា បាទ វាជារឿងធម្មតាទេ។ អ៊ីចឹងបើគឺថាដើម្បីដោះស្រាយបាន គឺថាមេធាវីការពារក្ដីអាចដំឡើងពេលបួនដប់នាទីទៅ ដើម្បីអាចឲ្យសួរសំណួរបាន។ ក៏ប៉ុន្តែអង្គជំនុំជម្រះក៏ធ្លាប់បង្ហាញភាពបត់បែនហើយថា អាចឲ្យសួរបាន អ៊ីចឹងខ្ញុំគិតថាដូចមិនជាមានបញ្ហាទេ។ ក៏ប៉ុន្តែ នៅពេលដែលសុំឲ្យពេលវេលា ចង់និយាយថាឲ្យពេលវេលាទៅមេធាវីការពារក្ដីហ្នឹងស្មើនឹងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនេះ វាដូចជាមិនត្រឹមត្រូវទេ ព្រោះថាសវនាការនេះយើងនិយាយអំពីទុក្ខសោក ទោះបីជាពេលខ្លះយើងចូលអង្គហេតុបន្តិចបន្តួចក៏ដោយ ដូច្នេះសំណើរបស់មេធាវីការពារក្ដីនោះ បាទរាងបំផ្លើស

បន្តិចហើយ។ សុំពេលវេលាស្មើគ្នាមិនត្រឹមត្រូវទេ។ ហើយខាងព្រះរាជអាជ្ញាហ្នឹងក៏ដូចគ្នាដែរ ក៏មិនអាចបានពេលវេលាស្មើនឹងដើមបណ្តឹងរដ្ឋប្បវេណីដែរ។ លោកប្រធានខ្ញុំសុំចប់ត្រឹមនេះ។

**កញ្ញា អង់តា ហ្គីសសេះ**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញៗ! សូមអញ្ជើញលោកមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី!

[១០:២៦:៣៩]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកត់សម្គាល់បន្តិចបន្តួចទេដើម្បីពន្យល់ឲ្យច្បាស់តែម្តងអំពីរបៀបដែលយើងស្នើឲ្យធ្វើការកាលវិភាគសវនាការនេះ និងសុំស្នើដំណោះស្រាយមួយឲ្យពេញចិត្តទាំងអស់គ្នាគឺថា បើសិនជាអង្គជំនុំជម្រះគិតថាសំណើភាគីនោះសមស្រប។ បើកត្តាបីនៃការពិចារណារបស់យើងដែលដើម្បីចេញជាកាលវិភាគនៃការធ្វើសវនាការនេះ គឺថាដោយសារទី១ សវនាការលើព្យសនកម្មនេះគឺជាកត្តាសំខាន់ណាស់នៃការចូលរួមក្នុងសវនាការរបស់គាត់ ហើយដើម្បីពន្យល់ឲ្យគាត់ឲ្យគាត់ដឹងថាហេតុអីបានគាត់ចូលនៅក្នុងសវនាការនេះនៅក្នុងក្រុមរួម? ដូច្នេះជាការសំខាន់ណាស់គឺថានៅពេលណាមួយត្រូវតែនិយាយអំពីព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលរង គឺថាព្យសនកម្មផ្លូវចិត្ត ហើយនិងផ្លូវកាយ ហើយនិងសម្ភារៈដែលបញ្ជាក់ពីមូលហេតុនៃការចូលរួមរបស់គាត់។ ឧទាហរណ៍ដូចថានៅត្រាំកក់នោះ យើងមានដើមបណ្តឹងរដ្ឋប្បវេណីច្រើនណាស់ដែលត្រូវទទួលដោយសហចៅក្រមស៊ើបអង្កេតសម្រាប់វគ្គដែលយើងនិយាយអំពីត្រាំកក់ ហើយនិងក្រាំងតាចាន់នេះ យើងមានដើមបណ្តឹងរដ្ឋប្បវេណី៥១នាក់។ អ៊ីចឹងគឺថា យើងចង់ត្រូវតែស្នើឲ្យគាត់ផ្តល់សក្ខីកម្មច្រើនបំផុត ដើមបណ្តឹងរដ្ឋប្បវេណីច្រើនបំផុតនៅប៉ុន្មានថ្ងៃខាងមុខនេះ។

[១០:២៨:១៨]

ហើយចំណុចទី២ មូលហេតុទី២ គឺថា យើងចង់បង្ហាញពីលក្ខណៈពិសេសនៃសវនាការគឺថាផ្តោតទៅលើព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីតែម្តង គឺថាយើងចង់ធ្វើយ៉ាងម៉េចបែងចែក ក៏ដូចជាការប្រៀបធៀបគ្នាគឺថា អង្គហេតុ ហើយនិងព្យសនកម្ម ហើយអង្គហេតុ ហើយនិងព្យសនកម្មនេះពិបាកបែងចែកគ្នាណាស់។ ខ្ញុំឧទាហរណ៍ដែល កូប៉េ បានលើកឡើងថា យើងគិតថា ការបង្អត់អាហារ

ហ្នឹងវាជាព្យសនកម្ម។ ដូច្នេះ ដើមបណ្ដឹងរដ្ឋប្បវេណីនឹងនិយាយអំពីអាហារ របបអាហារនៅពេលដែលគាត់ឡើងមកនិយាយអំពីព្យសនកម្មដែលគាត់ទទួលរងនោះហើយ។ ហើយយើងគិតថា ព្យសនកម្មផ្លូវចិត្តហ្នឹងគឺថា កើតចេញពីការបាត់បង់ក្រុមគ្រួសាររបស់គាត់។ អ៊ីចឹង នៅពេលដែលគាត់និយាយពីការបាត់បង់ក្រុមគ្រួសាររបស់គាត់នោះ គឺវាជារឿងធម្មតាទេ ដែលគាត់និយាយអំពីលក្ខខណ្ឌ ឬក៏កាលៈទេសៈដែលក្រុមគ្រួសារគាត់បាត់ ស្លាប់ ឬក៏បាត់ខ្លួន។ អ៊ីចឹង គឺថាមានទំនាក់ទំនងមិនអាចកាត់ផ្ដាច់បានរវាងអង្គហេតុ ហើយនិងព្យសនកម្ម។ ដូច្នេះវាជាការចាំបាច់ណាស់ដែលសវនាការលើព្យសនកម្មនេះបង្ហាញពីទំនាក់ទំនងមិនអាចកាត់ផ្ដាច់បាននោះទេ។ អ៊ីចឹងខ្ញុំមិនយល់ស្របនឹងមេធាវីការពារក្ដីទេ ដែលនិយាយថាវាដូចតែគ្នានោះ។ អ្វីដែលខុសគ្នា គឺថាដើមបណ្ដឹងរដ្ឋប្បវេណីគាត់និយាយអំពីអ្វីដែលកើតឡើងចំពោះរូបគាត់តែប៉ុណ្ណោះទេ។ ហើយគាត់មិនបាននិយាយអំពីអ្វីដែលគាត់បានឃើញ បានដឹង បានឃើញទេ គាត់និយាយតែបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់។ ដូច្នេះនៅពេលដែលយើងនិយាយដូច្នេះនេះគឺថាវាវិសាលភាពយើងវាបង្រួមហើយ។ អាស្រ័យហេតុដូច្នេះហើយបានភាគីផ្សេងទៀតនោះអាចចោទសំណួរតែពេលដែលគាត់និយាយទៅពាក់ព័ន្ធអង្គហេតុនោះទេ។ ហើយដូច្នេះបើសិនជាក្នុងតែករណីនេះយើងមិនអាចបែងចែកពេលវេលាស្មើគ្នាបាននោះទេ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានពេលវេលាផ្សេង ភាគីការពារក្ដីបានពេលវេលាផ្សេង។ ហើយយើងមាន -- ចំពោះការតទល់គ្នា ដើមបណ្ដឹងរដ្ឋប្បវេណីនឹងមកផ្ដល់សក្ខីកម្មនៅថ្ងៃព្រហស្បតិ៍ និងថ្ងៃសុក្រនេះ គឺទើបមានការសួរតទល់គ្នា។ យើងត្រូវធ្វើយ៉ាងណាឲ្យមានតម្លាភាព បញ្ហាដែលចោទមកហ្នឹង ថាតើយើងត្រូវគោរពគោលការណ៍ចំពោះមុខនេះយ៉ាងម៉េច គឺថាចំពោះសវនាការនេះជាសវនាការលើព្យសនកម្ម។

[១០:៣១:២០]

បើតាមអនុស្សរណៈរបស់អង្គជំនុំជម្រះនោះ នៅខែមករា ឆ្នាំមុននេះគឺឯកសារ E315/1 នេះហើយដែលជំរុញឲ្យយើងធ្វើសំណើនេះ។ នៅក្នុងអនុស្សរណៈនេះ គឺថាអង្គជំនុំជម្រះរក្សាសិទ្ធិថាធ្វើយ៉ាងណាផ្ដល់លទ្ធភាពទៅភាគី ដើម្បីសួរដើមបណ្ដឹងរដ្ឋប្បវេណីបាន។ បើសិនជាមានអង្គហេតុថ្មីដែលត្រូវបានលើកឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏ដោយមាន ឬក៏នៅពេល -- ករណីដែលមានការចោទប្រកាន់ទៅលើជនជាប់ចោទជាដើម គឺកថាខណ្ឌ នៅកថាខណ្ឌ៨នៃអនុស្សរណៈហ្នឹង ដោយចុះនៅថ្ងៃ -- នៅខែធ្នូ ឆ្នាំ២០១៤។ ដើម្បីឲ្យយល់អំពីអ្វីដែលអង្គជំនុំជម្រះនិយាយអំពីអង្គហេតុថ្មីហ្នឹង យើងផ្អែកទៅលើអនុស្សរណៈកាលពី លេខឯកសារ 267/3 អនុស្សរណៈដែលចេញនៅពេលបន្ទាប់ពីមាន

សំណើរបស់មេធាវី ខៀវ សំផន ដែលសុំឲ្យស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ដែលនិយាយអំពីព្យសនកម្ម។ ហើយកាលណោះអង្គជំនុំជម្រះបានយល់ឃើញថា ជាអង្គហេតុថ្មី វាជាអង្គហេតុថ្មីធៀបទៅនឹងការសុំតាំងខ្លួនដើមបណ្តឹងជារដ្ឋប្បវេណី។ អ្វីដែលថ្មីបើធៀបទៅនឹងអ្វីដែលចម្លើយដើមបណ្តឹងរដ្ឋប្បវេណីនេះ គេហៅថាជាព័ត៌មានថ្មីហើយ។ អ៊ីចឹងសំណើនេះវាមានឈ្មោះថា -- អ៊ីចឹងយើងនឹងចាំស្តាប់ការកត់សម្គាល់របស់ដើមបណ្តឹងរដ្ឋ -- មេធាវីការពារក្តីតាមរយៈបណ្តឹងឧទ្ធរណ៍ក្រុម ខៀវ សំផន ក៏ដូចក្រុមជា នួន ជា ដែរ។ អ៊ីចឹងយើងកាលណោះយើងក៏មិនដឹងថា តើមេធាវីការពារក្តីហ្នឹងធ្វើសំណើនោះទេកាលនោះនោះ តែឥឡូវហ្នឹងឃើញធ្វើសំណើហ្នឹងហើយ។ ហើយមេធាវី នួន ជា នោះមើលទៅដូចជាមានពេលវេលាគ្រប់គ្រាន់ ដើម្បីសួរទៅដើមបណ្តឹងរដ្ឋប្បវេណី ទៅលើអង្គហេតុ។ ខៀវ សំផន ប្រហែលជាត្រូវការអង្គជំនុំជម្រះសម្រេចឲ្យបានច្បាស់លាស់បន្តិច ក៏ប៉ុន្តែចំពោះយើង យើងគិតថាជាសិទ្ធិអំណាចរបស់អង្គជំនុំជម្រះជាអ្នកសម្រេច ថាតើពេលវេលាដែលយើងស្នើនេះ ដើម្បីសម្រាប់ឲ្យភាគីផ្សេងទៀតនោះសមស្របយ៉ាងណានោះ វាអាស្រ័យលើអង្គជំនុំជម្រះ។ ក៏ប៉ុន្តែចំពោះយើងខ្ញុំ បើសិនជាសវនាការនោះ បើនិយាយឲ្យចំមែនទែនទៅ គឺថាបើកាលណាគោរពគោលការណ៍ចំពោះមុខកាន់តែខ្លាំង ក៏វាជាការល្អសម្រាប់យើងជាដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។

[១០:៣៤:២០]

ជាការពិតណាស់ ដែលវេលាដែលយើងស្នើសុំសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗហ្នឹង វាពេលវេលានេះខ្លីណាស់ សម្រាប់យើងក៏ដូចសម្រាប់ភាគីផ្សេងទៀតដែរ ៤០នាទីម្នាក់នេះតិចណាស់។ យើងគិតថា សូមឲ្យគាត់បន្ថយដោយយើងឥឡូវយើងធ្វើសវនាការត្រឹមតែម៉ោងដប់មួយកន្លះនោះទេ អ៊ីចឹងកាលណាយើងកាត់បន្ថយពេលវេលាសវនាការ យើងគឺពេលវេលានិយាយរបស់យើងក៏តិចដែរ។ អ៊ីចឹងៗខ្ញុំគ្រាន់តែសួរ ថាតើសំណើខ្ញុំប៉ុណ្ណោះនេះអាចឲ្យគោរពគោលការណ៍ទល់មុខបានដែរឬអត់? ហើយអាចរកយុត្តិធម៌បានដែរឬអត់? យើងបានរៀបចំខ្លួនត្រៀមលក្ខណៈ ដើម្បីស្នើសំណើមួយទៅអង្គជំនុំជម្រះ គឺចាប់ផ្តើមស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីពីរនៅរសៀលស្អែក ដើម្បីធ្វើឲ្យអង្គជំនុំជម្រះមានភាពបត់បែនច្រើន ក្នុងការគ្រប់គ្រងពេលវេលា បែងចែកពេលវេលាឲ្យភាគី។ បើសិនជាអង្គជំនុំជម្រះយល់ស្របទទួលសំណើនេះ យើងឥឡូវនេះយើងបានកំណត់ថាជ្រើសរើសដើមបណ្តឹងរដ្ឋប្បវេណីពីរនាក់ហើយ ដែលគាត់អាចមកផ្តល់សក្ខីកម្មស្អែករសៀលបាន ដែលយើង -- ដែលធ្វើឲ្យយើងមានពេលវេលាច្រើន មានភាពបត់បែនបានច្រើន ហើយភាគីការពារក្តី គាត់អាចចោទសំណួរដែលខ្លួនចង់សួរបាន

ទាក់ទងទៅនឹងអង្គហេតុដែលដើមបណ្ដឹងរដ្ឋប្បវេណីអាចលើកឡើង។ ដូច្នេះយើងៗបើកទ្វារចំហ យើងយល់ឃើញថា សំណើដែលបានស្នើឡើងនេះ ឆ្លើយតបទៅនឹងការបង្កាប់បញ្ហា ហើយនិងអនុស្សរណៈរបស់អង្គជំនុំជម្រះ។ ដូចឆ្នាំក្នុងសំណុំរឿងមុននេះ ០២/១ នោះ ក៏យើងបានធ្វើអ៊ីចឹងដែរ។

បើសិនជាអង្គជំនុំជម្រះយល់ឃើញថា សំណើរបស់យើងនេះត្រូវតែផ្លាស់ប្ដូរនោះ សំណើរបស់ -- ឥឡូវសំណូមពររបស់យើងនេះ គឺភាគីមិនមែនថាសុំ យើងគ្រាន់តែសុំថា ឲ្យស្ដាប់ដើមបណ្ដឹងរដ្ឋប្បវេណីនេះទាំងអស់ ថាយើងសុំស្នើធ្វើយ៉ាងម៉េចយ៉ាងណា ទុកថាអាចស្ដាប់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងប្រាំបីនាក់នេះ។ ខ្ញុំយល់ឃើញថា គ្រាន់តែថាការផ្ដល់ពេលវេលាឲ្យមេធាវីការពារក្ដីស្នើគ្នានឹងយើងនេះមិនត្រឹមត្រូវទេ ព្រោះថាសវនាការនេះផ្ដោតតែទៅលើអ្វីដែលគាត់ឆ្លងកាត់ ហើយគាត់បានដឹង បានឃើញនៅពេលនោះទេ។ អ៊ីចឹងនៅទីបញ្ចប់ ដោយសុទ្ធចិត្តនោះ ខ្ញុំសូមឲ្យស្នើឲ្យចាប់ផ្ដើមស្ដាប់ដើមបណ្ដឹងរដ្ឋប្បវេណីពីររូប នៅរសៀលថ្ងៃស្អែក ដើម្បីឲ្យយើងមានពេលវេលាគ្រប់គ្រាន់ ដើម្បី ចោទសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ លោកប្រធាន។ ខ្ញុំគ្រាន់តែមានការកត់សម្គាល់ប៉ុណ្ណឹងទេលោកប្រធាន។ សូមបញ្ចប់ សូមអរគុណ។

[១០:៣៧:២៦]

**ប្រធានអង្គជំនុំៈ**

បាទ អរគុណ។ សូមអញ្ជើញមេធាវីការពារក្ដីលោក ខៀវ សំផន ។

**កញ្ញា អង់តា ហ្គីសសេៈ**

លោកប្រធាន ខ្ញុំសូមកែប្រែកំហុសខ្ញុំបន្តិចៗ។ អម្បាញ់មិញនេះ ខ្ញុំនិយាយថា ខ្ញុំយោងទៅនឹងសេចក្ដីសម្រេចមួយអំមិញនេះ គឺថាឯកសារ E3267/3 ដែលសហភាតាខ្ញុំអម្បាញ់មិញនេះ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី គាត់បានលើកឡើងដែរអម្បាញ់មិញពីឯកសារហ្នឹងអនុស្សរណៈហ្នឹងលោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េៈ**

សូមអរគុណ លោកប្រធាន។ ខ្ញុំមានការឆ្លើយតបទៅនឹងតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ក៏ដូចជាភាគីដើមបណ្ដឹងរដ្ឋប្បវេណី។ ទឡ្ហីករណ៍ដែលលើកឡើង ដែលៗការជំទាស់តវ៉ាដែលលើកឡើងថា សំណើរបស់ខ្ញុំយឺតពេលនោះ ខ្ញុំសូមរំឭកជូនអង្គជំនុំជម្រះផងថា សារណារបស់ខ្ញុំតាំងពីខែ ធ្វើតាំងពី២៩ ខែធ្នូ។ យើងបានដាក់សារណាបណ្ដឹងសាទុក្ខនេះ គឺមានការលើកឡើងនូវការជំទាស់តវ៉ាពេញលេញតែម្ដង។ ដូច្នេះភាគីទាំងពីរ ឬក៏ភាគីទាំងអស់នោះ គឺថាបានដឹងអំពីបញ្ហាដ៏ធំធេងនេះហើយ។ ក៏

ប៉ុន្តែនៅថ្ងៃទី១៦ ខែមករា ឆ្នាំនេះ ឯកសារ E336 យើងបានដាក់សំណើសុំមួយស្នើសុំអង្គជំនុំជម្រះ បានដែលអង្គជំនុំជម្រះបានសម្រេចរួចហើយ ហៅថាសំណើសុំទាក់ទងទៅនឹងការអនុវត្តមួយចំនួន ដែលត្រូវអនុវត្តនៅពេលដែលតាំងសំណួរទៅកាន់ TCCP-271គឺ សយ សែន។ ហើយនៅក្នុងកថាខណ្ឌ១២ គឺថាយើងបានលើកឡើងនូវការជំទាស់តវ៉ានេះរួចមកហើយ។ ដូច្នេះការជំទាស់តវ៉ានេះ គឺត្រូវភាគីទាំងអស់បានដឹងហើយ។ ខ្ញុំមិនដឹងថា ខ្ញុំតាមដានចំណុចដែលលើកឡើងថា មានការលើកឡើងថា សំណើសុំរបស់ខ្ញុំយឺតពេល។

[១០:៣៩:៣៤]

ចំណុចមួយទៀតដែលខ្ញុំចង់លើកឡើងផងដែរ គឺចំណុចដែលខ្ញុំមិនបានលើកទាំងពីខាងសហព្រះរាជអាជ្ញា ក៏ដូចជាដើមបណ្តឹងរដ្ឋប្បវេណី ដែលថាក្នុងការវិភាគរបស់យើងខ្ញុំដែលបានលើកឡើងនៅក្នុងសារណាបណ្តឹងសាទុក្ខ មានន័យថានៅក្នុងខាងសាលក្រម គឺផលព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានយកមកប្រើប្រាស់ចំនួន២៥០លើកឯណោះ។ នេះគឺជាការជំទាស់តវ៉ារបស់យើងខ្ញុំ។ ខ្ញុំមានចំណាប់អារម្មណ៍យ៉ាងខ្លាំង។ មានន័យថា យើងខ្ញុំហាក់បីដូចជាយល់ស្របជាមួយនឹងអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីនិយាយលើកឡើងអំពីផលប៉ះពាល់របស់ខ្លួន ដែលមិនមែនជាភស្តុតាងនោះទេ។ បើសិនណាជាករណីវាដូច្នេះមែន យើងខ្ញុំត្រូវគិតជាសារវន្តថា តើច្បាប់នោះមាននិយាយអំពីអ្វីដែលពាក់ព័ន្ធទៅនឹងចំណុចនេះ។ ដូចដែលខ្ញុំបានដកស្រង់ចេញពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទៅលើបញ្ហានេះរួចមកហើយ។ ខ្ញុំព្យាយាមធ្វើការអនុវត្តទៅតាមពេលវេលាកំណត់ដែលបានផ្តល់ឲ្យដល់អង្គជំនុំជម្រះ ប៉ុន្តែមិនមានវិធានកំណត់ច្បាស់លាស់ទេ ក៏ប៉ុន្តែអង្គជំនុំជម្រះកំណត់រួចមកហើយ ថាអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីនិយាយអ្វីជាផលប៉ះពាល់របស់ខ្លួននោះ គឺថាវាមិនមែនជាភស្តុតាងទាំងអស់នោះទេ។

[១០:៤០:៥៩]

លោកស្រីចៅក្រម ហ្វេនស៍ ឃើញសួរមកខ្ញុំថាហេតុអ្វី? ប្រសិនបើណាជាយើងខ្ញុំមាននិយាយអ្វីខុស សូមលើកឡើងនូវចំណុច អ្វីដែលយើងធ្វើទៅបាននោះ គឺយើងបានកំណត់ហើយថា អង្គជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១ បានប្រើប្រាស់សក្ខីកម្មប៉ះពាល់ទៅលើដើមបណ្តឹងរដ្ឋប្បវេណីចំនួន២៥០ដងរួចមកហើយ។ នេះគឺជាស្ថានភាពហ្នឹង។ បើសិនណាជាមិនពាក់ -- បើវាលើកឡើងតែផ្នែកនេះទេហ្នឹងជារឿងមួយ តែបើលើកផ្នែកពាក់ព័ន្ធផ្សេងទៀត យើងខ្ញុំនឹងស្នើសុំឲ្យមានសេចក្តីសម្រេចពាក់ព័ន្ធទៅនឹងលើបញ្ហានេះ។ ហើយយើងខ្ញុំក៏ត្រូវតែដឹងថាស្ថានភាពវាយ៉ាងដូចម្តេចដែរ។ ដោយពាក់ព័ន្ធទៅនឹង

កង្វះចំណីអាហារ ជាការពិតគឺវាជាភស្តុតាងហើយ កាលនិយាយពីចំណុចកង្វះចំណីអាហារនេះ។ យើងក៏ត្រូវតែមានឱកាសសួរផ្ទាល់ទៅលើដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។

**ប្រធានអង្គជំនុំ៖**

ចុះបញ្ហាសំណើសុំរបស់លោក កូប៉េ បញ្ហាសំណើសុំរបស់ក្រុមមេធាវីការពារក្តីដើមបណ្តឹងរដ្ឋប្បវេណី មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំធ្វើសវនាការនៅរសៀលថ្ងៃស្អែក ដើម្បីស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូប ក្នុងចំណោមប្រាំបីរូប ដែលគ្រោងធ្វើសវនាការនៅថ្ងៃខានស្អែក ថ្ងៃទី០២ និងទី០៣ ខែមេសា។

[១០:៤២:៤៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រហែលជាបញ្ហាពាក់ព័ន្ធទៅនឹងវិធីសាស្ត្រទេ។ ខ្ញុំយល់ឃើញថា យើងត្រូវដឹងថា តើនីតិវិធី និងច្បាប់និយាយថាម៉េច? ប្រសិនបើណាអង្គជំនុំជម្រះមានមតិយោបល់ថា អ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថាវាជា -- អ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងពាក់ព័ន្ធទៅនឹងព្យសនកម្មថាជាភស្តុតាងដូចដែលបញ្ជាក់នៅក្នុងសាលក្រម យើងត្រូវតែមានពេលវេលា។ ខ្ញុំយល់ឃើញថា បើដើមបណ្តឹងរដ្ឋប្បវេណីចាប់ផ្តើមសួរនៅថ្ងៃស្អែក យើងខ្ញុំក៏ត្រូវទទួលបាននូវពេលវេលាស្មើគ្នា។ ដូចដែលអង្គជំនុំជម្រះបញ្ជាក់ហើយ គឺថាមិនមានកន្លែងណាមួយដែលត្រូវយកសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធព្យសនកម្មថា ជាភស្តុតាងនោះទេ។

យើងមានពេលវេលាខ្លីមែនទែន ពាក់ព័ន្ធទៅនឹងនេះ សួរទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០១នោះ។ យើងមានពេលខ្លីណាស់ ហើយនៅក្នុងសារណារបណ្តឹងសាទុក្ខ នៅពេល នួន ជា ឈឺយ៉ាងខ្លាំង នៅក្នុងឆ្នាំ២០១៣ គាត់បាន ទោះបីជាឈឺក៏ដោយ គាត់បានស្នើថាឲ្យស្តាប់សក្ខីកម្មពាក់ព័ន្ធទៅនឹងព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណី។ ដោយសារថា ដូចដែលអង្គជំនុំជម្រះបញ្ជាក់ហើយ ដោយសារតែទាំងចម្លើយទាំងអស់នេះ មិនយកទៅប្រើប្រាស់ជាភស្តុតាងទាំងអស់នោះទេ ហើយនៅពេលនោះយើងខ្ញុំឆ្លើយថា អ៊ីចឹងមិនបញ្ហាទេ យើងអាចបន្តបាន។ ក៏ប៉ុន្តែយើងខ្ញុំមានការភ្ញាក់ផ្អើល នៅពេលដែលអវត្តមាននោះ គឺថាត្រូវគេយកមកប្រើប្រាស់ជាភស្តុតាងទៅវិញ។ ហ្នឹងជាស្ថានភាពដែលយើងខ្ញុំកំពុងតែប្រឈមមុខហើយ។ ប៉ុន្តែមុននឹងការប្រព្រឹត្តនូវការអនុវត្តជាក់ស្តែងណាមួយ យើងខ្ញុំស្នើសុំទៅអង្គជំនុំជម្រះថាតើមាននីតិវិធី ឬច្បាប់អ្វីដែលនិយាយពីបញ្ហានេះ។

[១០:៤៤:៥៣]

**ប្រធានអង្គជំនុំ៖**

ចុះមេធាវីដើមបណ្ដឹង -- អ៎! មេធាវីការពារក្ដីលោក ខៀវ សំផន បញ្ជាស្នើសុំស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីចំនួនពីររូបនៅថ្ងៃស្អែក ដោយក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដោយមូលហេតុភាគីការពារក្ដីទាមទារពេលវេលាស្មើគ្នានឹងពេលវេលាដែលដើម -- មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានឱកាសនៅក្នុងការសួរបន្ថែមទៅក្រុមដើមបណ្ដឹងរដ្ឋប្បវេណី ដែលនឹងមកថ្លែងទុក្ខសោកវេទនា ដែលអង្គជំនុំជម្រះកំណត់២ថ្ងៃ។ ការកំណត់២ថ្ងៃនេះ គឺពេលវេលាមានកំណត់ មានកំហិត ប្រសិនបើយើងធ្វើឲ្យបានត្រឹមត្រូវនោះ ពេលវេលាក្នុងការបន្ថែម ដើម្បីភាគីដទៃទៀតពាក់ព័ន្ធសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីនោះ មិនអាចប្រព្រឹត្តទៅបានទេ។ អ៊ីចឹងហើយដើម្បីឲ្យមានឱកាសក្នុងការប្រព្រឹត្តទៅបានសមស្របនោះ គឺសវនាការស្ដាប់ការថ្លែងទុក្ខ សោកវេទនារបស់ដើមបណ្ដឹងរដ្ឋប្បវេណី សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសូមឲ្យធ្វើចាប់ផ្ដើមពីរសៀលថ្ងៃស្អែកទៅ ដើម្បីឲ្យពេលវេលាវាគ្រប់គ្រាន់។ តើមានមតិយោបល់អ្វីទេលើផ្នែកនេះ ដែលបានស្នើអម្បាញ់មិញនេះ ព្រោះជាផ្នែកមួយដែលពាក់ព័ន្ធជាមួយនឹងការរៀបចំ ពិចារណាលើសំណើនេះ រួមទាំងការរៀបចំសវនាការឲ្យបានមានប្រសិទ្ធិភាពផងដែរ នៅចុងសប្ដាហ៍នេះ?

[១០:៤៦:២១]

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ពាក់ព័ន្ធទៅនឹងពេលវេលាដែលចាំបាច់សម្រាប់ការសួរដើមបណ្ដឹងរដ្ឋប្បវេណីនៅពេលត្រូវការនោះ។ ខ្ញុំគិតថា ខ្ញុំពិបាកនឹងការ -- ធ្វើការវាយតម្លៃណាស់ ពីព្រោះថាភាគច្រើននោះ ដើមបណ្ដឹងរដ្ឋប្បវេណីគាត់ធ្វើសេចក្ដីថ្លែងការណ៍មិនសូវលម្អិតសោះ ហើយអ៊ីចឹងខ្ញុំពិបាកក្នុងការផ្ដល់ផែន-ការថា យើងត្រូវការពេលប៉ុន្មានណាស់។ នេះជាចំណុចទី១ ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយប្រសិនបើមានភស្ដុតាងថ្មី ឬក៏មានធាតុផ្សំថ្មី ដែលមិនមែនជាបទពិសោធន៍ផ្ទាល់ខ្លួនរបស់ដើមបណ្ដឹងរដ្ឋប្ប-វេណីនោះ យើងនឹងសួរសំណួរ។ ចំណុចទី២ ខ្ញុំចង់ដឹងថា តើការធ្វើសវនាការនៅរសៀលស្អែកហ្នឹងយ៉ាងម៉េច? ខ្ញុំអាស្រ័យទៅលើការសម្រេចរបស់អង្គជំនុំជម្រះទេ។ យើងនៅទីក្រុងភ្នំពេញ អ៊ីចឹងបើពេលណាមានសវនាការ យើងអាចមកបាន។ អ៊ីចឹងខ្ញុំគិតថា ពេល -- ក៏ប៉ុន្តែពេលរសៀលនោះ ខ្ញុំគិតថាខ្ញុំមានពេលដើម្បីពិនិត្យមើលការបកប្រែឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ អ៊ីចឹងថ្ងៃនេះ ឬក៏ស្អែក

បើសិនជាអត់ធ្វើសវនាការ យើងអាចមានពេលពិនិត្យមើលឯកសារបាន ក៏ប៉ុន្តែអាស្រ័យទៅលើអង្គជំនុំជម្រះទេ ជាអ្នកសម្រេច ប៉ុន្តែធ្វើយ៉ាងណាសូមរក្សាសិទ្ធិភាគីផង។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សហព្រះរាជអាជ្ញារងកុំអាលទាន់។ ឥឡូវអស់ឌីវីឌីហើយ ផ្អាកមួយរយៈសិន ដើម្បីឱ្យខាងបុគ្គលិកផ្នែកខាងសោតទស្សន៍ផ្លាស់ប្ដូរឌីវីឌីថ្មី។

*(សម្រាករយៈពេលខ្លី ដើម្បីផ្លាស់ប្ដូរឌីវីឌីថ្មី)*

[១០:៤៨:៣៨]

បាទ ហើយសូមអញ្ជើញ សហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន ខ្ញុំនិយាយដោយខ្លីទេ។ យើងខ្ញុំអត់មានការជំទាស់ចំពោះការរៀបចំពេលវេលាឡើងវិញ ដើម្បីឱ្យដើមរដ្ឋប្បវេណីទាំងប្រាំបីអាចមកផ្ដល់សក្ខីកម្មបាននោះទេ ក៏ប៉ុន្តែនៅក្នុងដំណាក់កាលនេះ យើងពិបាកផ្ដល់ចម្លើយច្បាស់លាស់ណាស់។ អ៊ីចឹងប្រហែលជាអាចចំពោះស្អែកនុ៎ងយើងមិនជំទាស់ទេ ចំពោះសវនាការនៅរសៀលនោះ ហើយចំពោះឯកសារដែលមានតែមួយភាសានោះ ខ្ញុំគិតថា ដូចជាមិនពិតទេ។ ចំពោះដើមបណ្ដឹងរដ្ឋប្បវេណីទាំងប្រាំបីនោះ ខ្ញុំរកឃើញឯកសារបកប្រែជាភាសាបារាំង ឬជាភាសាអង់គ្លេស ឬបើសិនយើងព្យាយាមស្វែងរកនូវហ្សាយឡេបនោះ យើងអាចរកឃើញ។ ដូច្នេះ បើសិនជាខាងមេធាវីការពារក្ដីរកឯកសារមិនឃើញទេ អាចមកជួបខ្ញុំបាន ខ្ញុំអាចប្រាប់បានឯកសារអង់គ្លេស និងបារាំងនោះ គឺមាន។ សូមអរគុណ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំមានការកត់សម្គាល់តូចមួយ។ សូមអរគុណលោកប្រធានដែលផ្ដល់វេទិកានេះ ឱ្យខ្ញុំម្ដងទៀត។ តាមការលើកឡើងរបស់លោក កូប៉េ នោះគឺនិយាយអំពីបញ្ហានៅតុលាការកំពូល។ អ៊ីចឹង កាលដែលអង្គជំនុំជម្រះសាលាដំបូងបានប្រើសេចក្ដីថ្លែងការណ៍អំពីព្យសនកម្មនៅក្នុងសាលក្រម វាមិនពាក់ព័ន្ធនឹងយើងនៅថ្ងៃនេះទេ វាពាក់ព័ន្ធនឹងបណ្ដឹងសាទុក្ខឯណោះ ហើយយើងក៏បានឆ្លើយតបមួយចំណុចម្ដងៗទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី នួន ជា រួចមកហើយ។ យើងមិនឯកភាពទៅនឹងការវិភាគជាច្រើនរបស់គាត់ទៅលើចំណុចនេះ។ ក៏ប៉ុន្តែខ្ញុំគិតថាមិនគួរណាយកបញ្ហាហ្នឹងមកពិភាក្សានៅទីនេះទេ នៅថ្ងៃនេះទេ ខ្ញុំលើកឡើងនូវគោលជំហររបស់ខ្ញុំដដែល គឺជាចម្បងរបៀបវារៈដែលស្នើបាន

ស្នើឡើងនោះគឺវាស្របទៅតាមសំណើ ហើយនិងស្របទៅតាមអនុសាសន៍របស់អង្គជំនុំជម្រះ យុត្តិ-សាស្ត្ររបស់អង្គជំនុំជម្រះ។ ប្រសិនបើអង្គជំនុំជម្រះគិតថាត្រូវការពេលវេលាច្រើនដើម្បីឲ្យភាគីរៀបចំការសួរសំណួររបស់ខ្លួននោះ យើងៗបានកំណត់ដើមបណ្តឹងរដ្ឋប្បវេណីពីរនាក់ហើយ ខ្ញុំអាចផ្តល់ឈ្មោះឥឡូវនេះក៏បាន ឬក៏ផ្តល់តាមអ៊ីម៉ែលតាមក្រោយពេលសម្រាកក៏បានដែរ។ ពួកគាត់អាច គឺថាអាចសួរបាននៅថ្ងៃស្អែកពេលរសៀលនេះតែម្តង ពីរនាក់។

[១០:៥១:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

នេះគឺជាអ្វីដែលបាននិយាយនៅក្នុងសារណាបណ្តឹងសាទុក្ខ នៅដំណាក់កាលនៃបណ្តឹងសាទុក្ខ ខ្ញុំចង់ដឹងអំពីកំហុសដែលអាចមានឡើង ដែលនាំឲ្យមានការធ្វើសេចក្តីសន្និដ្ឋានខុស។ នៅកថាខណ្ឌ១៨៩ គឺការជំទាស់តវ៉ាចម្បង គឺនូវអ្វីអង្គជំនុំជម្រះបានលើកឡើង ក៏ប៉ុន្តែតាមការពិតនោះ គឺថាកថាខណ្ឌនេះ ឬក៏សេចក្តីសម្រេចដោយអង្គជំនុំជម្រះ គឺនិយាយអំពីសាក្សីអត្តចរិតគឺនិយាយច្បាស់ហើយ។ បើលោកមើលឯកសារយោង គឺថាមានការដកស្រង់គឺនិយាយអំពីសាក្សី 723 នោះគឺនិយាយជាសាក្សីអត្តចរិត។ នេះគឺនិយាយអំពី នេះគឺជាសាក្សីអត្តចរិត ហើយក្រោយមកលោកដកស្រង់យុត្តិសាស្ត្រអន្តរជាតិ ខ្ញុំមិនលើកឡើងយកមកនិយាយទេ។ ហើយនៅក្នុងកថាខណ្ឌ១៩៣ បើសិនណាជាអង្គជំនុំជម្រះមិនប្រាប់ទៅជនជាប់ចោទថា សក្ខីកម្មរបស់ជនរងគ្រោះគឺនិយាយគ្នាតែព្យសនកម្ម នោះមេធាវីមិនជំទាស់នោះទេ។ នេះមិនមែនជាការយោងខុសនោះមួយទេ។ តើនៅកន្លែងណាមួយ មាននៅកន្លែងមួយដែលអង្គជំនុំជម្រះនិយាយថា ផលប៉ះពាល់ទៅដល់ជនរងគ្រោះគឺថា ត្រូវយកមកពិចារណាសម្រាប់តែការផ្តន្ទាទោសតែប៉ុណ្ណោះ។ បើសិនណាជាលោកបញ្ជាក់ចំណុចនេះប្រហែលជាអាចនឹងជួយឲ្យមានការបញ្ជាក់បំភ្លឺទៅបានច្បាស់ ឲ្យបានយល់បានច្បាស់។

[១០:៥៣:២៤]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនរំពឹងថា អង្គជំនុំជម្រះទទួលយកកំហុសអង្គច្បាប់។ ខ្ញុំមិនមានជំហរអ្វីនិយាយ ខ្ញុំមិនមែនក្រោកឡើងឆ្លើយតបភ្លាមដូចដែលអ្វីដែលលោកស្រីចៅក្រមលើកឡើងនេះទេ ប៉ុន្តែខ្ញុំកត់សម្គាល់ថា មាន

ការយោងមួយផ្សេងទៀតដែលត្រូវបានដកស្រង់នៅក្នុងកថាខណ្ឌ១៨៩។ នេះគឺអ្វីដែលយើងបានយល់ អ្វីដែលលោក នួន ជា ក៏បានយល់ ហើយគាត់បានសួរថា មិនប្ដឹងទេ បើនិយាយតែពីផលប៉ះពាល់ទៅលើដើមបណ្ដឹងរដ្ឋប្បវេណី។ ហ្នឹងគឺជាអ្វីដែលយើងយល់ឃើញ។

ហើយជាថ្មីម្ដងទៀតបើសិនជាលោកស្រីចៅក្រម ដែលថាការយល់ឃើញរបស់យើងមិនត្រឹមត្រូវ ការដែលគ្រាន់តែនិយាយថា បានឃើញដូច្នេះ បានស្ដាប់នេះបានស្ដាប់នោះ បានឮអ៊ីចេះបានឮអ៊ីចុះ គឺយើងសុំធ្វើការជំទាស់តវ៉ា ហើយភាគីដទៃទៀតអាចកែតម្រូវខ្ញុំ។ ខ្ញុំគិតឃើញថានេះវាជាមធ្យោបាយមួយដែលថា ផលប៉ះពាល់សក្ខីកម្មប៉ះពាល់ទៅលើដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានលើកឡើងហ្នឹង។ ហើយបើសួរថាតើយើងសម្អាងទៅលើបញ្ហាអ្វីនោះ ថាយើងនឹងជួបប្រទះនូវស្ថានភាពមួយទៀតដែរ។ ខ្ញុំយល់ស្រប។ ឥឡូវនេះបើសិនជានិយាយថា អ្វីក៏ដោយដែលនិយាយនៅក្នុងពេលសួរពាក់ព័ន្ធទៅនឹងផលប៉ះពាល់ទៅលើដើមបណ្ដឹង បន្ទាប់មកទៀតគឺថា វាច្បាស់ហើយសម្រាប់យើង យើងត្រូវការពេលវេលាស្មើគ្នាទៅនឹងភាគីដទៃទៀត។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ហើយសំណួររបស់ខ្ញុំទាក់ទងទៅនឹងការអនុវត្តមួយ គឺសួរទៅសហមេធាវីនាំមុខ តើយើងយល់យ៉ាងដូច្នេះត្រឹមត្រូវទេ ថាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ដែលបានស្នើសុំដើម្បីឲ្យនិយាយអំពីការឈឺចាប់ ការរងទុក្ខ ការថ្លែងទុក្ខនោះ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ដើម្បីឆ្លើយតបទៅនឹងសំណួរនេះ ដោយមិនគិតទៅដល់អ្វីដែលពួកគាត់នឹងនិយាយនោះទេ គឺថាពួកគាត់ទាំងអស់ត្រូវបានទទួលយកជាជនរងគ្រោះដោយផ្ទាល់នៃត្រាំកក់។ ដូច្នេះពួកគាត់ទាំងអស់អាចនិយាយអំពីបញ្ហាដែលអាចគិតថាជាបញ្ហាអង្គហេតុដែរ លោកស្រីចៅក្រម។

[១០:៥៦:៣០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ! បាទ ចុងក្រោយហើយណ៎ា!

**លោក ឌេល លីសាក់៖**

ខ្ញុំគ្រាន់តែសូមឆ្លើយតបនូវអ្វីដែលលោក វ៉ិចទ័រ កូប៉េ បានលើកឡើង។ ខ្ញុំមានការចងចាំ ខ្ញុំកំពុងតែស្វែងរកនូវប្រតិចារឹកដ៏ច្រើនពាក់ព័ន្ធនឹងបញ្ហានេះ។ ប៉ុន្តែខ្ញុំបានមកតតាំងនៅចំពោះមុខអង្គជំនុំជម្រះ

មិនថាតែចំណុចនេះទេ តែក៏ចំណុចអង្គហេតុនុ៎ងដែរ។ គឺថាយើងមានការយល់បានដូចៗគ្នាយ៉ាងច្បាស់រួចមកហើយ ខ្ញុំមិនឲ្យមានការតឹងមាត់តឹងកអីដាក់គ្នានោះទេ។ ខ្ញុំបានស្រាវជ្រាវរកនៅក្នុងប្រតិចារឹកហើយខ្ញុំគិតថានេះជាចំណុចមួយសំខាន់ណាស់។ ប៉ុន្តែខ្ញុំមិនយល់ស្របនូវអ្វីមេធាវីការពារក្តីលើកឡើងអម្បាញ់មិញនោះទេ ដែលថាផលប៉ះពាល់ទៅលើជនរងគ្រោះ គឺអាចត្រូវប្រើ ឬយកមកប្រើប្រាស់ជាភស្តុតាងបាន។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៥៧:៥៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះជម្រាបអំមិញហើយ ថាសហព្រះរាជអាជ្ញារងអន្តរជាតិអំមិញ គឺភាគីដែលនិយាយចុងក្រោយដែលអង្គជំនុំជម្រះត្រូវការស្តាប់ហើយ។

បាទ អង្គជំនុំជម្រះសូមអរគុណចំពោះរាល់មតិយោបល់ សារណារបស់ភាគីពាក់ព័ន្ធទៅនឹងសំណើសុំរបស់មេធាវីការពារក្តីលោក នួន ជា ដែលបានលើកឡើងអម្បាញ់មិញនេះ ហើយអង្គជំនុំជម្រះនឹងលើកយកបញ្ហានេះទៅពិនិត្យពិចារណា ហើយនិងសម្រេចក្នុងពេលសមស្របខាងមុខនេះ។ ហើយរួមទាំងសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលសុំឲ្យអង្គជំនុំជម្រះមានការកែសម្រួលនូវកាលវិភាគសវនាការ មកដំណើរការស្តាប់សក្ខីកម្មដើមបណ្តឹង -- មកស្តាប់សេចក្តីថ្លែងទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូបនៅក្នុងចំណោមប្រាំបីរូបនៅរសៀលថ្ងៃស្អែក ដែលតាមកាលវិភាគយើងគ្រោងធ្វើនៅថ្ងៃខានស្អែក ថ្ងៃទី០២ និងទី០៣ ខែមេសា។ ដូច្នេះ អង្គជំនុំជម្រះក៏យកបញ្ហានេះទៅពិចារណា ហើយនិងជម្រាបជូនដំណឹងដល់ភាគីបានជ្រាបតាមរយៈអ៊ីម៉ែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងផងដែរ។

បាទ ហើយសវនាការនៅថ្ងៃនេះដល់ពេលត្រូវឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី០១ ខែមេសា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបីព្រឹក។ សវនាការនៅថ្ងៃស្អែកនេះអង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី រីឆាដ ឌុដម៉ាន តាមរយៈប្រព័ន្ធសោតទស្សន៍ពីសហរដ្ឋអាមេរិកមក សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយអង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបគឺលោក នួន ជា

និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបី។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១១:00 នាទី)*